សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីត្រៀមសម្រាប់ការ ទាញហេតុផល

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ផុន ផាន្នី**

សាស្ត្រាចារ្យណែនាំ

លោក **ភេត សុជាតិ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីត្រៀមសម្រាប់ការ ទាញហេតុផល

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ផុន ផាន្នី**

សាស្ត្រាចារ្យណែនាំ

លោក **កេត សុជាតិ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ ផុន ផានី ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០២០ បានសរសេរសារណាក្នុងគោលបំណងដើម្បីបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីអំពី «**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**»។

**នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

លោកឪពុក និងអ្នកម្តាយ ជាទីគោរព ដែលមាននូវមហាឧបការគុណដ៏ឧត្តុង្គឧត្តមធំធេងបំផុតគ្មានអ្វីប្រៀបផ្ទឹម និងមិនអាចបំភ្លេចបានឡើយ ព្រោះលោកទាំងពីរជាអ្នកមានគុណដោយបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ ព្រមទាំងទំនុកបម្រុងសព្វសារពើទាំងអស់ឱ្យកូនតាំងពីតូចរហូតដល់ធំ ហើយលោកទាំងពីរបានអប់រំ ណែនាំ និងទូន្មានប្រៀនប្រដៅកូនឱ្យចេះដឹងខុសត្រូវធ្វើជាមនុស្សល្អនៅក្នុងសង្គម។ ក្រៅពីនេះ លោកទាំងពីរក៏បានជំរុញនឹងលើកទឹកចិត្តឱ្យកូនខិតខំប្រឹងប្រែងរៀនសូត្រ ដោយបានបញ្ជូនកូនទៅរៀននៅទីក្រុង ព្រោះចង់បំពេញក្តីស្រមៃរបស់កូន ព្រមទាំងបានឧបត្ថម្ភកូនគ្រប់បែបយ៉ាង ទាំងកម្លាំងកាយកម្លាំងចិត្ត ថវិកា និងសម្ភារៈសម្រាប់ការសិក្សារហូតកូនបញ្ចប់បរិញ្ញាបត្រ ព្រមទាំងបានសរសេរសារណាមួយនេះ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ** ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តអស់ពីសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រង និងបង្ហាត់បង្រៀនរូបនាងខ្ញុំឱ្យមានចំណេះដឹង និងបទពិសោធន៍យ៉ាងជាច្រើន នៅអំឡុងពេលសិក្សាដើម្បីជាស្ពានរហូតឈានដល់ការសរសេរសារណានេះឡើង។

លោកសាស្ត្រាចារ្យ កេត សុជាតិ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ណែនាំបង្ហាត់បង្ហាញ ពន្យល់ កែតម្រូវ និងបានបង្កឱ្យមានលក្ខណៈងាយស្រួលដល់ការសរសេរសារណានេះឡើង។

ជាចុងក្រោយ នាងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងពួងលើលោកនេះឱ្យតាមជួយថែរក្សាអ្នកមានគុណទាំងទ្វេ ព្រមទាំងលោកគ្រូអ្នកគ្រូឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលាកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ដោយធ្លាប់សិក្សានៅថ្នាក់បរិញ្ញាបត្រឆមាសទី១ ឆ្នាំទី៤ នូវមុខវិជ្ជានីតិវិធីរដ្ឋប្បវេណីតាមកម្មវិធីសិក្សានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងការស្រាវជ្រាវបន្ថែមពាក់ព័ន្ធទៅនឹង **នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** នាងខ្ញុំមានចំណាប់អារម្មណ៍ទៅលើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាខ្លាំង។ ដើម្បីស្របតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ នាងខ្ញុំបានសម្រេចចិត្តសរសេរសារណាបញ្ចប់ការសិក្សា ដោយបានជ្រើសរើសយកប្រធានបទមួយស្តីអំពី «នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល» បើយោងទៅតាមច្បាប់ ការសិក្សាកន្លងមក និងសាស្ត្រាចារ្យដែលបានចូលរួមផ្តល់ជាយោបល់ល្អៗសម្រាប់នាងខ្ញុំ ដើម្បីឱ្យលេចចេញជារូបរាងឡើង ទុកជាឯកសារមួយដែលមានសារៈសំខាន់ និងអត្ថប្រយោជន៍សម្រាប់និស្សិតជំនាន់ក្រោយៗអាចយកទៅសិក្សារៀនសូត្រទៅអនាគត បើទោះបីជាមានគុណប្រយោជន៍តិចក្តីច្រើនក្តី។ ស្នាដៃមួយនេះគឺជាស្នាដៃដំបូងចំពោះនាងខ្ញុំដែលជានិស្សិតច្បាប់មួយរូប ដើម្បីបញ្ជាក់នូវចំណេះដឹង ដែលនាងខ្ញុំបានខិតខំប្រឹងប្រែសិក្សាថ្នាក់បរិញ្ញាបត្រអស់រយៈពេលបួនឆ្នាំមកនេះ។

ការជ្រើសរើសយកប្រធានបទនេះ ដោយសារតែនាងខ្ញុំយល់ឃើញថា តថភាពនៅក្នុងសង្គមជាក់ស្តែងមានការកើតឡើងនូវវិវាទជាច្រើនពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរយើង។ នៅក្នុងនីតិវិធីរដ្ឋប្បវេណីមាននីតិវិធីជាច្រើនទៀតដូចជា ការដាក់ពាក្យបណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការចេញសាលក្រម។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ជួយសម្រួលដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់យ៉ាងច្រើន ដែលនីតិវិធីនេះទាមទារឱ្យភាគីពិភាក្សាដេញដោលចំពោះមុខភាគី និងឱ្យភាគីដាក់ភស្តុតាង។

នាងខ្ញុំសង្ឃឹមថាឯកសារមួយនេះពិតជាអាចផ្តល់អត្ថប្រយោជន៍ទៅដល់អ្នកអាន និងសម្រាប់សិស្សប្អូនជំនាន់ក្រោយ សិក្សាស្រាវជ្រាវបន្ថែមពាក់ព័ន្ធនឹងប្រធានបទនេះ។ ឯកសារមួយនេះមិនទាន់ល្អឥតខ្ចោះនៅឡើយនោះទេ ដែលអាចនៅចំណុចខ្វះខាតមួយចំនួនដោយមិនបានធ្វើការស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ប៉ុន្តែនាងខ្ញុំសង្ឃឹមថា សារណាមួយនេះអាចរួមចំណែកមួយនៅក្នុងការសិក្សារបស់និស្សិតជំនាន់ក្រោយ។

ជាទីបញ្ចប់ នាងខ្ញុំរីករាយនឹងទទួលការរិះគន់ពីគ្រប់មជ្ឈដ្ឋាននានាក្នុងគោលបំណងដើម្បីស្ថាបនា និងកែលម្អនូវរាល់កំហុសឆ្គងទាំងឡាយពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងឡាយដោយក្តីគោរពរាប់អាន។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**១.១ និយមន័យ គោលបំណង និងសារៈប្រយោជន៍ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ៣

១.១.១ និយមន័យ ........ ៣

១.១.២ គោលបំណង ........ ៣

១.១.៣ សារៈប្រយោជន៍ ........ ៣

**១.២ គោលការណ៍មូលដ្ឋាន** ........ ៤

១.២.១ គោលការណ៍ឯករាជ្យនៃអំណាចតុលាការ ........ ៤

១.២.២ គោលការណ៍នៃការជម្រះក្តីតាមច្បាប់ ........ ៥

១.២.៣ គោលការណ៍នៃការធានាសិទ្ធិពឹងពាក់តុលាការ ........ ៦

១.២.៤ គោលការណ៍នៃការធានាសិទ្ធិទាមទារឱ្យសាកសួរ និងសវនាការ ........ ៦

១.២.៥ គោលការណ៍ចំពោះមុខ ........ ៧

១.២.៦ គោលការណ៍នៃការទទួលខុសត្រូវរបស់តុលាការ និងភាគី ........ ៧

១.២.៧ ភាសាដែលប្រើក្នុងតុលាការ និងសិទ្ធិទាមទារឱ្យមានការបកប្រែភាសារបស់ភាគី ........ ៨

១.២.៨ ការចូលរួមរបស់តំណាងអយ្យការ ........ ៩

## ជំពូកទី២
## ការចាប់ផ្តើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**២.១ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ១០

២.១.១ ការកំណត់កាលបរិច្ឆេទដោយតុលាការ ........ ១០

២.១.២ ការផ្លាស់ប្តូរកាលបរិច្ឆេទ ........ ១១

**២.២ ការកោះហៅភាគី និងបង្គាប់ឱ្យដាក់ឯកសារត្រៀម** ........ ១២

២.២.១ ការកោះហៅភាគី ........ ១២

២.២.១.១ ការបង្គាប់ឱ្យបង់ប្រាក់ជាមុនសម្រាប់កោះហៅ ........................................................ ១២
២.២.១.១ វិធីកោះហៅ ........................................................................................................ ១៣
២.២.២ ការបង្គាប់ឱ្យដាក់ឯកសារត្រៀម ............................................................................. ១៤
**២.៣ ការអនុវត្តកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**................... ១៤
២.៣.១ ការផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ......................................... ១៥
២.៣.២ ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី ........................................................................ ១៦
២.៣.២.១ សេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ................................................................ ១៦
២.៣.២.២ សេចក្តីថ្លែងការណ៍របស់ភាគីចុងចម្លើយ.............................................................. ១៧
២.៣.៣ ការរៀបចំ និងកំណត់ចំណុចវិវាទ ............................................................................ ១៨
២.៣.៣.១ ការរៀបចំការអះអាងរបស់ភាគី ......................................................................... ១៨
២.៣.៣.២ ការកំណត់ចំណុចវិវាទ ..................................................................................... ១៩
២.៣.៤ ការរៀបចំភស្តុតាង .................................................................................................. ២០
២.៣.៤.១ ការស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង .................................................................. ២០
២.៣.៤.២ ការសម្រេចទៅលើភស្តុតាង ................................................................................. ២០

## ជំពូកទី៣

## ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**៣.១ ពេលវេលាដែលត្រូវបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ..................... ២៤
៣.១.១ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបំពេញ ........................ ២៤
៣.១.២ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់បំពេញ ........................ ២៤
**៣.២ សកម្មភាពដែលត្រូវបំពេញនៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ................................................................................................................ ២៦
៣.២.១ ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ ............................................................ ២៦
៣.២.២ ការកំណត់កាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើកទី១ ............................ ២៧
**៣.៣ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.................................. ២៧
៣.៣.១. ការលើកចោលមធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួន ............................................ ២៧

៣.៣.២ ករណីលើកលែង ........................................................................................................ ២៨
**សេចក្ដីសន្និដ្ឋាន**............................................................................................................ ៣០
**អនុសាសន៍**.................................................................................................................. ៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាទូទៅក្នុងរឿងរដ្ឋប្បវេណី នៅពេលមានវិវាទកើតឡើងភាគីអាចធ្វើការផ្សះផ្សាគ្នាបាន គឺតុលាការគ្មានសិទ្ធិជ្រៀតជ្រែកក្នុងរឿងឯកជននោះទេ ប៉ុន្តែតុលាការអាចធ្វើការដោះស្រាយទៅលើវិវាទនោះបាន នៅពេលដែលភាគីបានធ្វើការដាក់ពាក្យបណ្តឹងមកតុលាការ ទើបតុលាការអាចជ្រៀតជ្រែកក្នុងវិវាទនោះបាន។ បន្ទាប់ពីទទួលបានពាក្យបណ្តឹង តុលាការនឹងធ្វើការពិនិត្យពាក្យបណ្តឹងរួចកំណត់កាលបរិច្ឆេទធ្វើការជំនុំជម្រះ ដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីធានាឱ្យបាននូវការជម្រះក្តីប្រកបដោយសុចរិត និងយុត្តិធម៌ជូនភាគី។ ការជំនុំជម្រះនេះ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ បានចែងថា មុនពេលឈានដល់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន។

តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាអ្វី? នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាការស្វែងរកចំណុចដែលភាគីមានវិវាទនឹងគ្នា ដោយការរៀបចំជាមុននៅការអះអាងរបស់ភាគី និងធ្វើការរៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ ដែលនឹងត្រូវធ្វើការពិនិត្យ និងវិនិច្ឆ័យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ឱ្យមានភាពឆាប់រហ័ស គ្មានភាពស្មុគស្មាញ ល្អិតល្អន់ និងមានភាពយុត្តិធម៌។ ប៉ុន្តែ ចំពោះរឿងក្តីចំនួនទឹកប្រាក់តិចដែលមានគោលបំណងដោះស្រាយវិវាទឱ្យបានឆាប់រហ័ស តាមនីតិវិធីសង្ខេប ដោយតុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ភ្លាម បន្ទាប់ពីទទួលបានពាក្យបណ្តឹង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវមានការចូលរួមពីតុលាការដែលជាអ្នកដឹកនាំចាត់ចែងនីតិវិធី ក្នុងករណីដែលរឿងក្តីត្រូវជំនុំជម្រះដោយក្រុមប្រឹក្សា គឺប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវដឹកនាំនីតិវិធី ប៉ុន្តែប្រសិនបើរឿងក្តីជំនុំជម្រះដោយចៅក្រមទោល គឺចៅក្រមនោះជាអ្នកដឹកនាំនីតិវិធី។ ទន្ទឹមនឹងនោះ ភាគីដើមចោទ និងភាគីចុងចម្លើយ ក៏ជាតួអង្គដ៏សំខាន់ផងដែរ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលត្រូវធ្វើសកម្មភាពដើម្បីឱ្យតុលាការអាចធ្វើការកំណត់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរបស់ខ្លួននៅក្នុងរឿងក្តី។ នៅក្នុងនីតិវិធីនេះទៀតសោតទាំងតុលាការ និងភាគី ត្រូវគោរពនូវគោលការណ៍សំខាន់ៗដូចជាគោលការណ៍ចំពោះមុខ គោលការណ៍យុត្តិធម៌ និងឆាប់រហ័ស គោលការណ៍អសាធារណៈ គោលការណ៍សិទ្ធិចាត់ចែងរបស់ភាគី និងគោលការណ៍នៃការប្រើប្រាស់សិទ្ធិបំភ្លឺ ជាដើម ។

សារណានេះ និងធ្វើការបង្ហាញត្រឹមតែនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល របស់តុលាការនៅសាលាដំបូងជាន់ទាបប៉ុណ្ណោះ ដោយមិនធ្វើការបកស្រាយទៅដល់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅតុលាការជាន់ខ្ពស់នោះទេ។ នីតិវិធីនេះធ្វើឡើងក្នុងគោលបំណង ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍នូវវិស័យច្បាប់

របស់ព្រះរាជាណាចក្រកម្ពុជា និងរំលេចចេញនូវនីតិវិធី ដែលជាប្រយោជន៍ចំពោះការអនុវត្តរបស់តុលាការ។ ជាងនេះទៅទៀតគឺ ដើម្បីទុកជាឯកសារសម្រាប់សិស្សប្អូនជំនាន់ក្រោយធ្វើការសិក្សាស្រាវជ្រាវ ក៏ដូចជាការយល់ដឹងពីបច្ចុប្បន្នភាពនៃការ វិវត្តន៍នៃវិស័យច្បាប់របស់កម្ពុជា។

ការស្រាវជ្រាវស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ នាងខ្ញុំបានចងក្រងឡើង ដោយបែងចែកជា ៣(បី) ជំពូកធំៗគឺ៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ជំពូកទី២៖ ការចាប់ផ្តើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ជំពូកទី៣៖ ការបញ្ចប់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ខ្លឹមសារនៃជំពូកនីមួយៗខាងលើនេះ និងបង្ហាញជូនទាំងស្រុងក្នុងសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំដូចខាងក្រោម។

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់
# ការទាញហេតុផល

# ជំពូកទី១

# សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការដោះស្រាយរឿងក្តីរដ្ឋប្បវេណី នីតិវិធីនៃការជំនុំជម្រះរឿងក្តីផ្តោតសំខាន់ទៅលើនីតិវិធីចំនួនបី សំខាន់ៗ គឺមានដូចជា៖ នីតិវិធីនៃការដាក់ពាក្យបណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែប្រធានបទនេះបកស្រាយតែទៅលើ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុណ្ណោះ មិនធ្វើការបកស្រាយទៅលើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ។ ក្នុងនេះក៏មានការបកស្រាយចំណុចចំនួន០២ គឺ និយមន័យ គោលបំណង និងសារៈប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (១.១) និងគោលការណ៍ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (១.២)។

## ១.១ និយមន័យ គោលបំណង និងសារៈប្រយោជន៍ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១.១.១ និយមន័យ

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាដំណាក់កាលដំបូងមួយ នៃនីតិវិធីរដ្ឋប្បវេណីដែលធ្វើឡើង ដើម្បីផ្តល់ឱកាសដល់គូភាគីថ្លែងការណ៍អំពីពាក្យបណ្តឹងរបស់ខ្លួន ត្រៀមរៀបចំសេចក្តីអះអាង បំភ្លឺនូវចំណុចវិវាទ ដែលភាគីយល់មិនស្រប និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទ នៅមុនពេលចាប់ផ្តើមកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់។

### ១.១.២ គោលបំណង

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្រប និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យ បានល្អិតល្អន់។[1]

### ១.១.៣ សារៈប្រយោជន៍

សារៈប្រយោជន៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺដើម្បីផ្តល់សមភាព និងភាពយុត្តិធម៌ដល់ភាគីនៃវិវាទ តាមរយៈការជួបគ្នាផ្ទាល់នៅពេលតែមួយ និងកន្លែងតែមួយ ដើម្បីធ្វើការអះអាងអំពីអង្គហេតុ និងការដាក់ភស្តុតាងជូនតុលាការ។ មួយវិញទៀត នីតិវិធីនេះអាចធ្វើការជម្រះក្តីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មិនមានភាពស្មុគស្មាញ ពីព្រោះតុលាការអាចស្នើឱ្យភាគីដកការអះអាងអំពីអង្គហេតុណាដែលមិនមានសារៈប្រយោជន៍ចំពោះការសម្រេចសេចក្តី និងអាចផាត់ចោលនូវអង្គហេតុណាដែលភាគីធ្វើការអះអាងដូចគ្នា ដោយ

[1] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១០៣

ចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ។ ការដែលនាំឱ្យមានភាពស្មុគស្មាញគឺថា នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីនីមួយៗតែងតែលើកឡើងនៅអង្គហេតុ ផ្សេងៗដែលខ្លួនយល់ឃើញថាមានសារៈប្រយោជន៍សម្រាប់ខ្លួនឯង ដោយពុំបានគិតថាអង្គហេតុទាំងនោះមាន ឬគ្មានសារៈសំខាន់ចំពោះរឿងក្ដីនោះទេ។ ស្របពេលជាមួយគ្នានេះផងដែរ ភាគីនីមួយៗតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង។ ក៏ប៉ុន្តែការធ្វើបែបនេះនឹងនាំឱ្យមានភាពស្មុគស្មាញ និងអូសបន្លាយដោយឥតប្រយោជន៍ និងធ្វើឱ្យមានការលំបាកក្នុងស្វែងរកការពិត។[2] ជាងនេះទៅទៀតតុលាការអាចចម្រាញ់យកតែភស្តុតាងណាដែលសំខាន់ និងមានតម្លៃសម្រាប់អង្គហេតុតែប៉ុណ្ណោះ។[3]

ដោយហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅមុនការជម្រះក្ដីដោយការទាញហេតុដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន។

## ១.២ គោលការណ៍មូលដ្ឋាន

គោលការណ៍ជាមូលដ្ឋាន គឺជាគោលគំនិត ឆន្ទៈនយោបាយសាធារណៈរបស់រដ្ឋ ដែលមានលក្ខណៈចាប់បង្ខំចង្អុលបង្ហាញ និងចង្អុលចំពោះប្រព័ន្ធនៃបណ្ដាបទប្បញ្ញត្តិនៃនីតិវិធី និងស្ដែងឡើងនូវលក្ខណៈពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយផ្ដើមចេញពីទស្សនៈឆន្ទៈរបស់រដ្ឋចំពោះស្ថានភាពរបស់សង្គមជាក់ស្ដែង បណ្ដាបទដ្ឋានគតិយុត្តដែលមានតម្លៃខ្ពស់បំផុតគឺរដ្ឋធម្មនុញ្ញ ច្បាប់ដែលជាបទដ្ឋានជាន់ខ្ពស់ ដូចជាច្បាប់ចាត់តាំងតុលាការជាអាទិ៍ ច្បាប់ពាក់ព័ន្ធដទៃទៀត គោលនយោបាយឯកជន រួមទាំងតម្រូវការ និងការទាមទាររបស់សង្គមជាតិ និងអន្តរជាតិផងដែរ។ និយាយដោយឡែក គោលការណ៍ជាមូលដ្ឋាន អាចចាត់ទុកជាគ្រោងឆ្អឹងនៃច្បាប់ដែលទ្រទ្រង់ប្រព័ន្ធច្បាប់ទាំងមូលឱ្យមានជំហររឹងប៉ឹង និងមានចលនារស់រវើកនៅពេលដែលច្បាប់នោះចូលអនុវត្ត។

ក្រមនីតិវិធីរដ្ឋប្បវេណី ពឹងផ្អែកទៅលើគោលការណ៍ជាមូលដ្ឋានមួយចំនួនដូចខាងក្រោម ហើយដែលជាគោលការណ៍មូលដ្ឋាននៃនីតិរដ្ឋប្រជាធិបតេយ្យផងដែរ។

### ១.២.១ គោលការណ៍ឯករាជ្យនៃអំណាចតុលាការ

អំណាចតុលាការ ជាអំណាចឯករាជ្យ[4] ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ[5]។

---

[2] សេចក្ដីពន្យល់អំពីក្រមនីតិវិធីកម្ពុជា ភាគ១ ស្ដីពីនីតិវិធីនៃបណ្ដឹង ឆ្នាំ២០០៨ ទំព័រ៧៤

[3] ក្រមនីតិវិធីរដ្ឋប្បវេនៃព្រះរាជាណាចក្រកម្ពុជាណី ឆ្នាំ២០០៦ មាត្រា ១២៧

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៨ថ្មី កថាខណ្ឌទី១

[5] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៣២ថ្មី កថាខណ្ឌទី២

អំណាចតុលាការគ្រប់គ្រងទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។[6] គោលការណ៍ឯករាជ្យនៃអំណាចតុលាការ ត្រូវបានទទួលស្គាល់ថាជាគោលការណ៍ជាមូលដ្ឋាន មិនត្រឹមតែនៅក្នុងបទដ្ឋានគតិយុត្តជាតិតែប៉ុណ្ណោះទេ វាក៏ត្រូវបានទទួលស្គាល់ដោយបទដ្ឋានគតិយុត្ត ដែលមានលក្ខណៈជាសកលដែលអង្គការសហប្រជាជាតិបានអនុម័ត។[7] គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី គឺការការពារសិទ្ធិរបស់បុគ្គលឯកជន តាមរយៈវិធានចាប់បង្ខំមួយដោយតុលាការ ដើម្បីដោះស្រាយនូវវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ ដើម្បីធានារក្សាអនាគតិ ការពារសិទ្ធិសេរីភាព និងផលប្រយោជន៍ស្របច្បាប់ របស់ប្រជាពលរដ្ឋ និងផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋបាននោះចៅក្រម ដែលជាអ្នកទទួលបាននូវអំណាចតុលាការ ត្រូវស្ថិតនៅក្នុងស្ថានភាពមិនលំអៀង ត្រូវបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងពុំទទួលបាននូវការជ្រៀតជ្រែក និងទទួលឥទ្ធិពលពីសំណាក់ស្ថាប័នរដ្ឋបាលណាមួយ ឬពីសំណាក់ភាគីណាមួយនៃរឿងក្តីឡើយ។ ម្យ៉ាងទៀតចៅក្រមត្រូវបានធានានូវឋានៈរបស់ខ្លួនពោលគឺមិនអាចត្រូវដកពីតំណែងដោយសារលទ្ធផល នៃការបំពេញមុខងារចៅក្រមបានឡើយ លើកលែងតែចៅក្រមនោះ បានប្រព្រឹត្តបទល្មើសជាក់ស្តែង នោះទើបឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យទៅលើចៅក្រមនោះបាន។ ការធានាឯករាជ្យនៃអំណាចតុលាការ ពោលគឺចៅក្រម និងឋានៈរបស់ចៅក្រម គឺជាគោលការណ៍មូលដ្ឋានមួយនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

### ១.២.២ គោលការណ៍នៃការជម្រះក្តីតាមច្បាប់

ច្បាប់ជាទូទៅ ដែលនៅក្នុងនោះរួមមានទាំងក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ ត្រូវបានអនុម័តដោយសភាដែលជាតំណាងឱ្យពលរដ្ឋខ្មែរដែលជាម្ចាស់នៃសិទ្ធិ។ ពិតមែនតែឯករាជ្យភាពរបស់ចៅក្រមត្រូវបានធានាដោយច្បាប់ ប៉ុន្តែពុំមែនមានន័យថាចៅក្រមអាចយកអំណាចឯករាជ្យនេះ មកប្រើប្រាស់ជាពិសេសនៅក្នុងការដោះស្រាយបណ្តឹងរដ្ឋប្បវេណី តាមតែទំនើងចិត្តរបស់ខ្លួនបាននោះទេ។ ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន[8] មានន័យថា ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់សារធាតុដែលជាមូលដ្ឋាននៃការជម្រះក្តី ត្រូវតែបានអនុវត្តបានដោយតឹងរ៉ឹង និងត្រូវបានបកស្រាយដោយមានការឯកភាពគ្នាបំផុត សម្រាប់ចៅក្រមគ្រប់រូប ដែលមានសមត្ថកិច្ចដោះស្រាយបណ្តឹងរដ្ឋប្បវេណី។ ដើម្បីឆ្លើយតបការទាមទារនៃរដ្ឋធម្មនុញ្ញនោះគោលការណ៍នៃការជម្រះក្តីតាមច្បាប់ត្រូវបានទទួលស្គាល់ និងបញ្ញត្តិជាក់ស្តែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។[9]

[6] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៨ថ្មី កថាខណ្ឌទី៣

[7] សៀវភៅស្តីអំពី នីតិវិធីរដ្ឋប្បវេណី រៀបរៀងដោសាស្ត្រាចារ្យ ហ៊ី សោភា។

[8] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៃមាត្រា១២៩ថ្មី កថាខណ្ឌទី១

[9] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២ កថាខណ្ឌទី១

### ១.២.៣ គោលការណ៍នៃការធានាសិទ្ធិពឹងពាក់តុលាការ

នៅក្នុងជីវភាពរស់នៅក្នុងសង្គម ជាពិសេសសង្គមសេដ្ឋកិច្ចទីផ្សារសេរី នោះបុគ្គលម្នាក់ៗធ្វើសកម្មភាពសេដ្ឋកិច្ចដើម្បីទ្រទ្រង់ជីវៈភាពរស់នៅរបស់ខ្លួន តាមរយៈការគ្រប់គ្រងមធ្យោបាយផលិតកម្ម ការដោះដូរ និងសកម្មភាពសេវាផ្សេងៗទៀត ពោលគឺភាគច្រើនតាមរយៈកិច្ចសន្យារវាងមនុស្ស និងមនុស្ស។ ក្នុងនាមជាពលរដ្ឋនៃនីតិរដ្ឋប្រជាធិបតេយ្យ មនុស្សត្រូវគោរពនូវការសន្យា ស្មោះត្រង់ និងសុចរិត ពោលគឺ គោរពតាមអ្វីៗ ដែលច្បាប់បានកំណត់ និងវិធានផ្សេងទៀត ដូចជាសីលធម៌ សាសនា ទំនៀមទម្លាប់ ប្រពៃណីជាអាទិ៍។ ប៉ុន្តែបាតុភូតដែលកើតឡើង នៅក្នុងទំនាក់ទំនងសង្គមនេះ មិនមែនសុទ្ធតែមានលក្ខណៈវិជ្ជមានដូចដែលប៉ងប្រាថ្នានោះឡើង ដូចនេះទំនាស់បានកើតមានឡើង ហើយទំនាស់ទាំងនោះត្រូវតែនាំយកទៅដោះស្រាយដោយវិធានផ្សេងៗគ្នាតាមតែភាគីមានទំនាស់ចង់បាន ដើម្បីឈានទៅរកលទ្ធផលដែលអាចទទួលយកបាន។ នៅពេលដែលវិធាននៃការដោះស្រាយវិវាទដោយខ្លួនឯង និងអាចទទួលយកបាន។ នៅពេលដែលវិវាទនៃការដោះស្រាយវិវាទដោយខ្លួនឯង និងអាចទទួលយកបានពីសំណាក់សង្គមដូចជាការសះជា ឬតាមផ្លូវមជ្ឈការ ឬសន្ធានកម្មពុំទទួលបានលទ្ធផល នោះភាគីទំនាស់ ជាពិសេសភាគីដែលយល់ថាសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួនត្រូវបានបំពាន មានសេរីភាព និងសិទ្ធិជ្រើសរើសយកវិធាននៃការដោះស្រាយទំនាស់តាមផ្លូវតុលាការដែលជាវិធានការដោះស្រាយដោយបង្ខំបាន។ ដូចនេះសិទ្ធិពឹងពាក់តុលាការ គឺជាសិទ្ធិរបស់ពលរដ្ឋ តែមិនមែនជាអំណាចពលរដ្ឋដែលផ្តល់បុគ្គលឯកជននោះឡើយ។ យោងតាមទស្សនៈរបស់រដ្ឋដែលប្រកបដោយប្រជាធិបតេយ្យនោះការពារសិទ្ធិរបស់បុគ្គលឯកជន គឺជាកាតព្វកិច្ចរបស់រដ្ឋ ឯពលរដ្ឋវិញ នៅក្នុងករណីដែលសិទ្ធិរបស់ខ្លួនត្រូវបានបំពាននោះបុគ្គលនេះមានសិទ្ធិទទួលយកការជម្រះក្តីរបស់តុលាការ ដើម្បីទទួលបានការការពារសិទ្ធិពីរដ្ឋតាមរយៈការដាក់ពាក្យប្តឹងទៅតុលាការ។

### ១.២.៤ គោលការណ៍នៃការធានាសិទ្ធិទាមទារឱ្យសាកសួរ និងសវនាការ

ជាការពិតបណ្តឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ ការធានាសិទ្ធិពឹងពាក់តុលាការ ក៏ជាការទាមទារមួយព្រមគ្នានូវនីតិវិធីដោះស្រាយ និងសម្រេចសេចក្តីមួយដែលប្រកបដោយយុត្តិធម៌។ សេចក្តីសម្រេចរបស់តុលាការមានលក្ខណៈចាប់បង្ខំឱ្យភាគីមួយទទួលយកនូវពេលដែលសេចក្តីសម្រេចនោះមានអានុភាព ពោលគឺភាគីនៃបណ្តឹងរដ្ឋប្បវេណី ទទួលឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន ដោយសេចក្តីសម្រេចរបស់តុលាការ ដូចនេះភាគីត្រូវមានឱកាសដើម្បីបញ្ចេញមតិរបស់ខ្លួន ចំពោះចំណុចដែលនឹងត្រូវវិនិច្ឆ័យដោយតុលាការ និងឆ្លើយតបចំពោះមតិដែលបញ្ចេញដោយភាគីម្ខាងទៀត មុនពេលមានការសម្រេចសេចក្តី។ ការធានាសិទ្ធិទាមទារអោយសាកសួរជាគោលការណ៍

មូលដ្ឋាននៃប្រព័ន្ធនីតិវិធីបណ្ដឹង នៅក្នុងរដ្ឋប្រជាធិបតេយ្យសម័យទំនើបបានប្រកាន់យក ដូចជាច្បាប់មូលដ្ឋាននៃប្រទេសអាឡឺម៉ង់ និងក្រមរដ្ឋប្បវេណីនៃប្រទេសបារាំងជាដើម។[10]

មានករណីពិសេសខ្លះ នោះគោលការណ៍ធានានូវសិទ្ធិទាមទារឱ្យសាកសួរត្រូវបានលើកលែង ដោយការទាមទារឱ្យដោះស្រាយដោយឆាប់រហ័សនូវបញ្ហាមួយចំនួន ដែលអនុញ្ញាតឱ្យតុលាការធ្វើការសម្រេចសេចក្ដីជាមុនរួចហើយទើបសាកសួរភាគី ដែលអាចទទួលរងនូវការខូចខាតដោយ ការសម្រេចសេចក្ដីនោះនៅពេលក្រោយ ដូចជាការសម្រេចសេចក្ដីតាមរូបភាពដីកាសម្រេចដាស់តឿន[11] ពាក្យសុំដីកាសម្រេចដាស់តឿន ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[12] ជាអាទិ៍។

ដូចគ្នាផងដែរ ការធានាសិទ្ធិសវនាការ គឺជាសិទ្ធិមួយ ជាមូលដ្ឋានមួយរបស់ភាគីដែលត្រូវបានទទួលស្គាល់ដោយក្រមនីតិវិធីរដ្ឋប្បវេណី ហើយដែលជាការផ្ដល់ឱកាសឱ្យភាគីអាចបញ្ចេញនូវមតិរបស់ខ្លួន និងឆ្លើយតបទៅនឹងមតិរបស់ភាគីម្ខាងទៀត នៅមុនពេលដែលតុលាការជាទៅដល់ការសម្រេច ជាចុងក្រោយចំពោះការទាមទាររបស់ភាគីណាមួយ។

### ១.២.៥ គោលការណ៍ចំពោះមុខ

ដើម្បីធានានូវសិទ្ធិទាមទារ ឱ្យសាកសួរ ឱ្យមានប្រសិទ្ធិភាព ការជម្រះក្ដីត្រូវតែធ្វើឡើងដោយកោះហៅភាគីទាំងសងខាងឱ្យមកបង្ហាញខ្លួននៅក្នុងកាលបរិច្ឆេទតែមួយ ហើយត្រូវឱ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់។ ប្រសិនបើអនុញ្ញាតឱ្យតុលាការអាចកោះហៅតែម្ខាង ហើយស្ដាប់ការអះអាងរបស់ភាគីនោះ ដោយពុំមានវត្តមានរបស់ភាគីម្ខាងទៀត នោះអាចនឹងប៉ះពាល់ទៅដល់ទំនុកចិត្តរបស់ភាគី ទៅលើយុត្តិធម៌នៃការវិនិច្ឆ័យ។ ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា ជាគោលការណ៍ តុលាការអាចត្រូវវិនិច្ឆ័យ ដោយគោរពតាមគគោលការណ៍ចំពោះមុខ ពោលគឺត្រូវកោះហៅភាគីទាំងសងខាង ឱ្យភាគីទាំងសងខាងថ្លែងពីអំណះអំណាងរបស់ខ្លួន និងជជែកតតាំងគ្នាទៅវិញទៅមក[13]។ ចំពោះគោលការណ៍ចំពោះមុខនេះ ក៏មានករណីលើកលែងមួយចំនួនដែរ (មាត្រា២០០, មាត្រា២០១, មាត្រា៣២៣ កថាខណ្ឌទី១ ជាដើម។

### ១.២.៦ គោលការណ៍នៃការទទួលខុសត្រូវរបស់តុលាការ និងភាគី

តុលាការត្រូវប្រឹងប្រែង ដើម្បីធានារ៉ាប់រងបណ្ដឹងរដ្ឋប្បវេណី ឱ្យប្រព្រឹត្តទៅដោយភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្ដឹងរដ្ឋប្បវេណីដោយសុចរិត និងស្មោះត្រង់។[14]

---

[10] សៀវភៅស្ដីអំពី នីតិវិធីរដ្ឋប្បវេណី រៀបរៀងដោសាស្ត្រាចារ្យ ហ៊ី សោភា។

[11] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣២៣

[12] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៥៤៥

[13] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣ កថាខណ្ឌទី២

[14] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៥

ក្នុងនាមជាអ្នកអនុវត្តនីតិវិធី តុលាការត្រូវប្រឹងប្រែង និងគប្បីជៀសវាងនូវការប្រើប្រាស់ពាក្យសម្តី ឬ ចំពោះណាដែលនាំឱ្យមានការសង្ស័យអំពីភាពយុត្តិធម៌។ យុត្តិធម៌យឺតយ៉ាវ ស្មើនឹងការបដិសេធនូវយុត្តិធម៌ ជាពាក្យសុភាសិតច្បាប់ដែលត្រូវទទួលស្គាល់ជាសកល ដូចនេះតុលាការមិនត្រឹមតែត្រូវប្រឹងប្រែងដោះស្រាយបណ្តឹង ពោលគឺដឹកនាំនីតិវិធីនៃបណ្តឹង ឱ្យប្រព្រឹត្តទៅដោយយុត្តិធម៌ប៉ុណ្ណោះទេ គឺថែមទាំងព្យាយាមអនុវត្តច្បាប់ស្តីពីនីតិវិធី ដោយឆាប់រហ័សទៀតផងនោះទើបជាការដោះស្រាយ ដោយយុត្តិធម៌ពិតៗ។

យុត្តិធម៌ និងឆាប់រហ័សជាគោលដៅពីរ ដែលជាការទទួលខុសត្រូវរបស់តុលាការ ដូចនេះ ទាមទារឱ្យតុលាការគប្បីធ្វើអោយមានការចុះសម្រុងគ្នា រវាងភាពឆាប់រហ័សនៃការអនុវត្តនីតិវិធី និងការទាមទារឱ្យមានភាពត្រឹមត្រូវនៃការសម្រេចសេចក្តី រួមទាំងនីតិវិធីនៃការសម្រេចសេចក្តី។

នៅក្នុងរបបបណ្តឹងរដ្ឋប្បវេណី ភាគីត្រូវទទួលស្គាល់ថាមានសេរីភាព និងមានសិទ្ធិចាត់ចែងបណ្តឹងរដ្ឋប្បវេណី ដើម្បីផលប្រយោជន៍របស់ខ្លួន ពោលគឺការទទួលបាននូវសាលក្រមដែលសម្រេចអោយខ្លួនឈ្នះក្តី។ ប៉ុន្តែភាគីមិនត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាពដោយទុច្ចរិត និងមិនស្មោះត្រង់ចំពោះភាគីម្ខាងទៀតឡើយ។ សកម្មភាពដែលផ្ទុយនឹងភាពសុចរិត ស្មោះត្រង់ ត្រូវបានវិនិច្ឆ័យដោយយោងទៅតាមករណីជាក់ស្តែងនីមួយៗ និងយោងទៅតាមបទបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានបញ្ញត្តិនឹងចាត់ទុកថាសកម្មភាពមួយចំនួនរបស់ភាគី គឺជាសកម្មភាពដែលផ្ទុយទៅនឹងភាពសុចរិត ស្មោះត្រង់ ហើយដែលលទ្ធផលរបស់សកម្មភាពទាំងនោះនឹងនាំមកនូវការខូចខាតប្រយោជន៍របស់ភាគីដែលបានធ្វើសកម្មភាពមិនត្រឹមត្រូវ។

### ១.២.៧ ភាសាដែលប្រើក្នុងតុលាការ និងសិទ្ធិទាមទារឱ្យមានការបកប្រែភាសារបស់ភាគី

ភាសា និងអក្សរ ដែលប្រើជាផ្លូវការ គឺភាសាខ្មែរ និងអក្សរខ្មែរ[15]។ នៅក្នុងនាមជាប្រជាពលរដ្ឋមួយប្រកបដោយអធិបតេយ្យភាព ឯករាជ្យភាព និងមិនអាចបំបែកបាន នោះព្រះរាជាណាចក្រកម្ពុជាមានភាសា និងអក្សររបស់ជាតិខ្លួនគឺ ភាសា និងអក្សរខ្មែរ ដែលត្រូវបានប្រើប្រាស់ជាផ្លូវការនៅក្នុងសកម្មភាពគ្រប់គ្រងរដ្ឋ។ តុលាការជាស្ថាប័នមួយដែល ទទួលអនុវត្តអំណាចមួយក្នុងចំណោមអំណាចទាំងបីរបស់រដ្ឋពោលគឺ អំណាចតុលាការ ដូចនេះភាសាដែលត្រូវប្រើក្នុងតុលាការ ត្រូវតែជាភាសាខ្មែរ។ ក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ញត្តិយកជាភាសាខ្មែរ ជាភាសាដែលត្រូវប្រើប្រាស់នៅក្នុងតុលាការ[16]។

ភាគីដែលមិនអាចយល់ជាភាសាខ្មែរ អាចស្នើសុំរកអ្នកបកប្រែភាសាដែលខ្លួនអាចយល់បាន។ សិទ្ធិទាមទារអោយសាកសួរសវនាការ និងគោលការណ៍ចំពោះមុខ ព្រមទាំងភាពយុត្តិធម៌ក្នុងការសម្រេចសេចក្តី និងមិនត្រូវធានាឡើយ ប្រសិនបើគេមិនអាចយល់បានអំពីបញ្ហា ដែលត្រូវបានលើកឡើងដោយភាគីម្ខាងទៀត ឬ

[15] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៥

[16] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៥ កថាខណ្ឌទី១

ដោយតុលាការប្រសិនបើគេមិនអាចយល់បាននូវភាសាខ្មែរ ដូចនេះសិទ្ធិទាមទារឱ្យមានការបកប្រែភាសារបស់ភាគីត្រូវបានទទួលស្គាល់ ថាជាគោលការណ៍មូលដ្ឋានមួយ ក្នុងចំណោមគោលការណ៍ជាមូលដ្ឋានផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយបញ្ហានេះរកអ្នកបកប្រែគឺជាបន្ទុករបស់រដ្ឋនៅក្នុងករណីដែលភាគីមិនមានលទ្ធភាពរកអ្នកបកប្រែដោយខ្លួនឯងបាន។

**១.២.៨ ការចូលរួមរបស់តំណាងអយ្យការ**

ជាគោលការណ៍តំណាងអយ្យការ គឺជាអ្នកតំណាងអោយផលប្រយោជន៍ជាសាធារណៈ ហេតុនេះប្រសិនបើមានការចាំបាច់ សម្រាប់ការពារផលប្រយោជន៍សាធារណៈ នោះតំណាងអយ្យការអាចចូលរួមក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បាន តាមការយល់ឃើញរបស់ខ្លួន ឬតាមរយៈការជូនដំណឹងរបស់តុលាការបាន។ ទស្សនៈតំណាងអយ្យការ ជាអ្នកតំណាងអោយផលប្រយោជន៍សាធារណៈ មិនមានន័យថាតំណាងអយ្យការចូលរួមក្នុងនីតិវិធីនៃបណ្តឹង ក្នុងនាមខ្លួនជាភាគីនៃបណ្តឹងនោះឡើយ។ ទស្សនៈនេះផ្ទុយគ្នាផងដែរជាមួយទស្សនៈដែលធ្លាប់មានពីមុនមក ដែលថាតំណាងអយ្យការជាអ្នកតំណាងដោយអាណត្តិនៅក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី ក្នុងករណីដែលភាគីជាអនីតិជនជាដើម។ អ្នកដែលត្រូវការពារផលប្រយោជន៍របស់អនីតិជនគឺជា អ្នកតំណាងដែលច្បាប់បានកំណត់ ដូចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាល ក្នុងករណីគ្មានអ្នកមានអំណាចមេបា ប៉ុន្តែមិនមែនជាអ្នកតំណាងអយ្យការឡើយ។

# ជំពូកទី២

# ការចាប់ផ្តើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

# ជំពូកទី២

# ការចាប់ផ្តើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ជាគោលការណ៍ សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្តឹង គឺជាសិទ្ធិអំណាចរបស់តុលាការ ហើយត្រូវអនុវត្តដោយតុលាការ។ ដើម្បីឱ្យនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអាចអនុវត្តបាន តុលាការត្រូវរៀបចំកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន (១) បន្ទាប់មកទៀតធ្វើការកោះហៅភាគី និងបង្គាប់ឱ្យដាក់ឯកសារត្រៀម (២) ជាមុនបាន។

## ២.១ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ដោយសារតែ តុលាការជាអ្នកដឹកនាំ និងចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[17] ហេតុនេះកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ត្រូវតែកំណត់ដោយតុលាការផងដែរ (២.១.១) ប៉ុន្តែកាលបរិច្ឆេទនេះក៏អាចបានផ្លាស់ប្តូរផងដែរ (២.១.២) ។

### ២.១.១ ការកំណត់កាលបរិច្ឆេទដោយតុលាការ

ដើម្បីរក្សានូវគោលគំនិតនៃនីតិវិធីរដ្ឋប្បវេណី ដែលកំពុងអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា នាពេលបច្ចុប្បន្ន ដែលការជំនុំជម្រះត្រូវបានធ្វើឡើង ក្រោយពីបានឆ្លងកាត់ដំណាក់កាលនៃការសាកសួរ។ ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ថា នៅពេលបណ្តឹងត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឱ្យបានយ៉ាងឆាប់រហ័ស និងធ្វើការកោះហៅភាគី។ ហើយកាលបរិច្ឆេទនេះ តុលាការត្រូវកំណត់ឱ្យបានក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងករណីដែលមានមូលហេតុពិសេស[18]។ ការកំណត់កាលបរិច្ឆេទបែបនេះ កើតចេញពីការគិតគូរដល់ភាគីដែលថាចុងចម្លើយនឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការពារខ្លួន និងថាការចាប់ផ្តើមនីតិវិធីត្រៀមនឹងមិនមានភាពយឺតយ៉ាវ។

ការកំណត់កាលបរិច្ឆេទនេះ តុលាការអាចកំណត់តាមពាក្យសុំ ឬកំណត់ដោយឆន្ទានុសិទ្ធិ។[19] ក្នុងករណីដែលមិនអាចជៀសវាងបាន កាលបរិច្ឆេទអាចកំណត់យកថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សំរាកផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្តបាន។[20] ហើយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើ

---

[17] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨៩ កថាខណ្ឌទី១

[18] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨០

[19] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៤០ កថាខណ្ឌទី១

[20] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៤០ កថាខណ្ឌទី២

ឡើង នៅកាលបរិច្ឆេទដែលភាគីអាចចូលរួមបាន។[21] បានន័យថា គោលការណ៍ចំពោះមុខ ត្រូវបានតុលាការធានាយ៉ាងពេញលេញនៅក្នុងនីតិវិធីនេះ ប៉ុន្តែតុលាការក៏អាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល បាន ទោះបីជាភាគីម្ខាងទៀតមិនមានវត្តមានក៏ដោយឱ្យតែតុលាការបានធ្វើការបញ្ជូនដីកាកោះ និងបានផ្តល់ឱកាសឱ្យភាគីនោះបង្ហាញខ្លួនត្រឹមត្រូវហើយ។ ក្នុងករណីពិសេសមានមូលហេតុដែលមិនអាចគោរពអំឡុងពេលនេះបាន ដូចជាគ្រោះថ្នាក់ធម្មជាតិ ឬស្ថានភាពនៃចុងចម្លើយដែលមិនអាចចូលរួមបាន ដោយជម្ងឺធ្ងន់ធ្ងរ នោះតុលាការអាចកំណត់កាលបរិច្ឆេទវែងជាងការកំណត់ខាងលើបាន។

ដើម្បីឱ្យភាគីបានដឹង និងចូលរួមតាមកាលបរិច្ឆេទនោះ តុលាការត្រូវធ្វើការកោះហៅ ហើយដែលបញ្ហានេះសម្រាប់ចុងចម្លើយនោះដីកាកោះហៅត្រូវបានបញ្ជូនភ្ជាប់ពាក្យបណ្តឹង។ ចំពោះដើមចោទតុលាការត្រូវបញ្ជូនដីកាកោះហៅ ដូចនេះតម្រូវឱ្យមានការបង់សោហ៊ុយសម្រាប់ការកោះហៅនេះ។ ករណីដើមចោទពុំបានបង់សោហ៊ុយសម្រាប់ធ្វើការបញ្ជូនដីកាកោះជាមុន ហើយមិនធ្វើតាមបង្គាប់របស់តុលាការក្នុងការបង់សោហ៊ុយទេនោះ តុលាការអាចលើកបណ្តឹងចោលដោយដីកាសម្រេច លុះត្រាតែគ្មានការតវ៉ាពីសំណាក់ចុងចម្លើយ។[22] ដីកាសម្រេចលើកបណ្តឹងចោលនេះ អាចប្តឹងជំទាស់បាន។

### ២.១.២ ការផ្លាស់ប្តូរកាលបរិច្ឆេទ

ករណីដែលតុលាការបានកំណត់កាលបរិច្ឆេទរួចហើយ តែភាគីបានដាក់ពាក្យសុំឱ្យតុលាការប្តូរកាលបរិច្ឆេទ ភាគីនោះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីមូលហេតុដែលត្រូវការប្តូរកាលបរិច្ឆេទនោះជាចាំបាច់។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនត្រូវបានអនុញ្ញាតប្តូរនោះទេ លើកលែងតែមានមូលហេតុមិនអាចជៀសវាងបាន ហើយកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកដំបូងអាចអនុញ្ញាតឱ្យបាន ប្រសិនបើមានការព្រមព្រៀងពីសំណាក់គូភាគី។[23] ដោយសារតែ ពេលដើមចោទដាក់ពាក្យបណ្តឹង តុលាការបានពិនិត្យពាក្យបណ្តឹង ហើយក៏កំណត់កាលបរិច្ឆេទលើកដំបូង ដោយមិនបានទាក់ទងទៅចុងចម្លើយជាមុន ហេតុនេះដើម្បីការពារផលប្រយោជន៍ចុងចម្លើយ ទើបអនុញ្ញាតឱ្យភាគីចុងចម្លើយសុំប្តូរកាលបរិច្ឆេទបាន ។

តុលាការក៏អាចពន្យារកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ប្រសិនបើយល់ឃើញថា អំឡុងពេលនៃការកោះហៅមានរយៈពេលខ្លីពេក ឬយល់ឃើញថា ភាគីមិនអាចមកបង្ហាញខ្លួនបានដោយគ្មាន

[21] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៥ កថាខណ្ឌទី១

[22] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨២ កថាខណ្ឌទី២

[23] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៤១

កំហុស។[24] មានន័យថា តុលាការត្រូវទុកឱកាសសមរម្យឱ្យភាគីមានលទ្ធភាពចូលបង្ហាញខ្លួនតាមកាលបរិច្ឆេទស្របតាមគោលការណ៍ចំពោះមុខ។

### ២.២ ការកោះហៅភាគី និងបង្គាប់ឱ្យដាក់ឯកសារត្រៀម

បន្ទាប់ពីបានកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រួចហើយតុលាការត្រូវធ្វើការកោះហៅភាគី (២.១) និងបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម (២.២) ជាមុនបាន ។

#### ២.២.១ ការកោះហៅភាគី

មុននឹងធ្វើការកោះហៅភាគី តុលាការនឹងបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីសិន ដើម្បីធ្វើជាសោហ៊ុយក្នុងការកោះហៅគូភាគី។ នៅក្នុងការកោះហៅ តុលាការត្រូវបង្គាប់ឱ្យដើមចោទបង់ប្រាក់ជាមុនសម្រាប់ធ្វើការកោះហៅ (២.១.១) និងត្រូវអនុវត្តនូវវិធីកោះហៅ (២.១.២) ឱ្យបានត្រឹមត្រូវ។

##### ២.២.១.១ ការបង្គាប់ឱ្យបង់ប្រាក់ជាមុនសម្រាប់កោះហៅ

ដោយសារតែវិវាទរដ្ឋប្បវេណីនេះ គឺជាវិវាទរវាងបុគ្គលឯកជន និងបុគ្គលឯកជន ហេតុនេះនៅក្នុងនីតិវិធីបណ្ដឹង ទើបភាគីដើមចោទដែលដាក់ពាក្យបណ្ដឹងត្រូវបង់ប្រាក់ប្រដាប់ក្ដីសម្រាប់ធ្វើការកោះហៅ។[25]

ក្នុងករណីតុលាការបានបង្គាប់ឱ្យដើមចោទបង់ប្រាក់ជាមុន ដែលចាំបាច់សម្រាប់ការកោះហៅដោយកំណត់អំឡុងពេលសមរម្យ តែដើមចោទមិនបានបង់ប្រាក់នោះជាមុនទេ តុលាការអាចលើកបណ្ដឹងចោលដោយដីកាសម្រេចបាន លុះត្រាតែចុងចម្លើយគ្មានការតវ៉ា។ មានន័យថា នៅក្នុងនីតិវិធីបណ្ដឹង ក្រោយពេលតុលាការធ្វើការបញ្ជូនពាក្យបណ្ដឹងទៅភាគីចុងចម្លើយរួចហើយ គឺដើមចោទត្រូវតែបង់ប្រាក់ប្រដាប់ក្ដីជាមុន (ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ) ដែលជាសោហ៊ុយចាំបាច់សម្រាប់តុលាការធ្វើការកោះហៅភាគី។ ប្រសិនបើដើមចោទមិនព្រមបង់ប្រាក់ប្រដាប់ក្ដីតាមការបង្គាប់របស់តុលាការជាមុនទេ តុលាការអាចលើកបណ្ដឹងចោលបាន ប៉ុន្តែបើមានការតវ៉ាពីចុងចម្លើយតុលាការមិនអាចលើកបណ្ដឹងចោលបានឡើយ ដោយហេតុថា ការលើកបណ្ដឹងនេះចោលធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ភាគីចុងចម្លើយដូចជា ចុងចម្លើយចង់បានសាលក្រមបញ្ជាក់ពីអង្គហេតុជាដើម។ ដោយចុងចម្លើយត្រូវបង់ប្រាក់ប្រដាប់ក្ដីឱ្យតុលាការសម្រាប់ធ្វើការកោះហៅភាគី ជំនួសដើមចោទ។ ចំពោះដីកាសម្រេចលើកបណ្ដឹងចោល ភាគីអាចប្ដឹងជំទាស់បាន ។[26]

---

[24] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០៣ កថាខណ្ឌទី១

[25] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៦២ កថាខណ្ឌទី២

[26] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨២ កថាខណ្ឌទី២

ប្រសិនបើដើមចោទ បានបង់ប្រាក់ប្រដាប់ក្តីតាមការបង្គាប់របស់តុលាការរួចហើយ តុលាការនឹងរៀបចំកោះហៅភាគី។ ការកោះហៅតាមកាលបរិច្ឆេទ ត្រូវធ្វើដោយបញ្ជូនដីកាកោះ ឬដោយជូនដំណឹងអំពីកាលបរិច្ឆេទទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលពាក់ព័ន្ធ។[27]

**២.២.១.១ វិធីកោះហៅ**

ការកោះហៅតាមកាលបរិច្ឆេទ ត្រូវធ្វើដោយបញ្ជូនដីកាកោះ ឬ ដោយការជូនដំណឹងអំពីកាលបរិច្ឆេទទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលពាក់ព័ន្ធ។[28] ហេតុដូចនេះ វិធីកោះហៅអាចធ្វើតាមៈ

**-ការជូនដំណឹងអំពីកាលបរិច្ឆេទ**

ការជូនដំណឹង គឺជាវិធីដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងវិធីនៃការបញ្ជូន ដោយអ្នកប្រតិបត្តិការបញ្ជូនអាចប្រើប្រាស់គ្រប់មធ្យោបាយបាន។

ចំពោះការជូនដំណឹង អំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលពាក់ព័ន្ធ មានន័យថា តុលាការត្រូវប្រាប់ដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនោះ។ ក្រៅពីនេះមាននីតិវិធីផ្សេងទៀតដែលងាយស្រួលដូចជា ធ្វើការប្រកាសតាមទូរស័ព្ទ អ៊ីម៉ែល ប្រៃសនីយ៍ តាមសំបុត្រធម្មតា តាមរយៈបុគ្គលិកនៃការិយាល័យមេធាវីជាដើម ដើម្បីឱ្យអ្នកត្រូវទទួលការបញ្ជូនបានដឹង ហើយក្នុងនោះនីតិវិធីនៃការបញ្ជូន ក៏ជាមធ្យោបាយមួយនៃការជូនដំណឹងដែរ។

**-ការបញ្ជូន**

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមនីតិវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ ប៉ុន្តែនីតិវិធីនេះត្រូវធ្វើឡើងតាមច្បាប់កំណត់ ដោយត្រូវតែមានរបាយការណ៍ស្តីពីការបញ្ជូន។ កិច្ចការបញ្ជូន ត្រូវធ្វើឡើងដោយក្រឡាបញ្ជី។ ក្រឡាបញ្ជីជាមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ហើយចាត់ចែងការបញ្ជូន ដោយប្រគល់អំណាច នៃការបញ្ជូនឯកសារទៅឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនរួមមានៈ

- បុគ្គលិកប្រៃសណីយ៍
- អាជ្ញាសាលា
- និងក្រឡាបញ្ជីខ្លួនឯង ។[29]

[27] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៤២
[28] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៤២
[29] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៤៦

ក្នុងការបញ្ជូនដីកាកោះ មន្ត្រីប្រតិបត្តិការបញ្ជូនពេលធ្វើការបញ្ជូនរួចត្រូវធ្វើរបាយការណ៍ស្តីពីការបញ្ជូនដីកាកោះនោះជូនតុលាការ ។[30]

### ២.២.២ ការបង្គាប់ឱ្យដាក់ឯកសារត្រៀម

ឯកសារត្រៀម គឺជាឯកសារសរសេរអំពីខ្លឹមសារដែលភាគីនឹងត្រូវថ្លែងការណ៍ នៅកាលបរិច្ឆេទបន្ទាប់ដើម្បីជូនដំណឹងជាមុនទៅភាគីម្ខាងទៀត និងតុលាការ។ គោលបំណងនៃឯកសារនេះ គឺឱ្យតុលាការ និងភាគីម្ខាងទៀតពិចារណាឱ្យបានគ្រប់គ្រាន់ អំពីខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ និងឱ្យត្រៀមខ្លួនចូលក្នុងកាលបរិច្ឆេទដើម្បីឱ្យការតតាំងនៅកាលបរិច្ឆេទមានការប្រព្រឹត្តទៅបានរលូន។ ដូច្នេះ គប្បីឱ្យភាគីដាក់ឯកសារនេះនៅពេលកំណត់មួយ ឱ្យបានមុនកាលបរិច្ឆេទ។

ជាការពិតពាក្យបណ្តឹងរបស់ដើមចោទ គឺជាឯកសារត្រៀមដែលដើមចោទដាក់មកតុលាការ ប៉ុន្តែតុលាការក៏អាចកំណត់ឱ្យដើមចោទដាក់ឯកសារត្រៀមផ្សេងទៀត ដើម្បីអះអាងពីចំណុចជាក់លាក់ណាមួយ បានផងដែរ។ ចំពោះចុងចម្លើយវិញ តុលាការអាចកំណត់អំឡុងពេលឱ្យដាក់ឯកសារត្រៀមលើកដំបូង ឬឯកសារត្រៀមដែលសរសេរអំពីការអះអាងជាក់លាក់ណាមួយ។[31] នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់លើកដំបូងត្រូវសរសេរអំពីការឆ្លើយតប ទៅនឹងខ្លឹមសារសាលក្រមដែលដើមចោទបានទាមទារ នៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ឬមិនទទួលស្គាល់នូវអង្គហេតុដែលដើមចោទសរសេរក្នុងពាក្យបណ្តឹង និងអង្គហេតុតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង ជាអាទិ៍។[32]

ឯកសារត្រៀម ជាឯកសារដែលតុលាការអាចបង្គាប់ឱ្យភាគីដាក់បាន ប៉ុន្តែ មិនមែនដាច់ខាតត្រូវតែដាក់នោះទេ ចំពោះឯកសារឆ្លើយតបក៏ដូចគ្នាដែរ។ ឧទាហរណ៍ថា ភាគីពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើឯកសារពេលនោះមានតែឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នៅកាលបរិច្ឆេទ។ ប៉ុន្តែដើម្បីឱ្យភាគីតតាំងគ្នាបានរលូននៅក្នុងកាលបរិច្ឆេទ ហើយការជំនុំជម្រះមានប្រសិទ្ធភាពល្អ ភាគីដែលមានសមត្ថភាពធ្វើឯកសារត្រៀម គួរតែបង្គាប់ឱ្យភាគីនោះដាក់ឯកសារត្រៀមមុនកាលបរិច្ឆេទ។

## ២.៣ ការអនុវត្តក្នុងកាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងរឿងក្តីរដ្ឋប្បវេណី ចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅពេលអនុវត្តក្នុងកាលបរិច្ឆេទនីតិវិធី គឺតុលាការត្រូវឆ្លងកាត់នីតិវិធីដូចខាងក្រោម៖

[30] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៤ កថាខណ្ឌទី១

[31] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០២

[32] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០១ កថាខណ្ឌទី៣

### ២.៣.១ ការផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវតែសាកល្បងធ្វើការផ្សះផ្សាលើកដំបូងជាមុនសិន លើកលែងតែយល់ឃើញថាមិនសមរម្យ។[33] ដោយសារតែ នីតិវិធីរដ្ឋប្បវេណីមានគោលបំណងកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬកាតព្វកិច្ចតាមច្បាប់សារធាតុ ដែលអាចចាត់ចែងបានដោយផ្អែកលើការព្រមព្រៀងរវាងភាគី ទោះបីជានៅពេលនីតិវិធីបណ្តឹងបានចាប់ផ្តើមក៏ដោយ ប្រសិនបើភាគីបានកំណត់ពីអត្ថិភាព ឬនត្ថិភាព សិទ្ធិនិងកាតព្វកិច្ចតាមរយៈការស្រុះស្រួលហើយភាគីសម្រេចចិត្តបញ្ចប់វិវាទនោះ គេអាចនិយាយបានថា វាជាលទ្ធផលដែលគួរឱ្យចង់បាន។ បានន័យថា ប្រសិនបើការផ្សះផ្សាទទួលបានលទ្ធផលនឹងផ្តល់ផលប្រយោជន៍ជាច្រើនដល់តុលាការ ភាគី ទាំងផ្នែកសេដ្ឋកិច្ច និងពេលវេលា។ ចំពោះភាគី គឺអាចរក្សាទំនាក់ទំនងល្អរវាងភាគីទាំងសងខាង ក្នុងករណីការផ្សះផ្សាបានជោគជ័យ។ ហេតុនេះហើយ បានក្រមនីតិវិធីរដ្ឋប្បវេណីចែងថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល សកម្មភាពដំបូងនៃការជម្រះក្តីតុលាការត្រូវតែណែនាំឱ្យភាគីសាកល្បងធ្វើការផ្សះផ្សាគ្នា។ ផ្ទុយទៅវិញ បើតុលាការយល់ឃើញថា ការព្យាយាមសាកល្បងផ្សះផ្សា មិនសមរម្យទេ ដូចជាក្នុងករណីដែលសិទ្ធិ ឬកាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង គឺជាប្រភេទនៃសិទ្ធិ ឬកាតព្វកិច្ចដែលមិនអាចចាត់ចែងបានដោយគ្រាន់តែផ្អែកលើការព្រមព្រៀងរបស់ភាគីប៉ុណ្ណោះទេ ឬក្នុងករណីដែលអាកប្បកិរិយារបស់គូភាគី បានបង្ហាញយ៉ាងច្បាស់ថា ពួកគេគ្មានឆន្ទៈក្នុងការផ្សះផ្សាទេនោះ តុលាការមិនចាំបាច់ណែនាំឱ្យភាគីធ្វើការផ្សះផ្សាគ្នាទៀតទេ។

ម្យ៉ាងវិញទៀត ប្រសិនបើតាមរយៈការវិនិច្ឆ័យអំពីស្ថានភាពនៃបណ្តឹង តុលាការយល់ឃើញថា វិវាទនោះអាចដោះស្រាយដោយការផ្សះផ្សាបាន តុលាការអាចសាកល្បងធ្វើការផ្សះផ្សា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅពេលក្រោយមក ឬ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តែម្តង ក៏បាន។[34] ពេលណែនាំឱ្យភាគីធ្វើការផ្សះផ្សាគ្នា តុលាការអាចប្រើវិធីសាស្ត្រឱ្យភាគីម្ខាងចេញពីបន្ទប់សិន ហើយឱ្យភាគីម្ខាងទៀតធ្វើការអះអាង រួចធ្វើបែបនេះម្តងទៀតចំពោះភាគីម្ខាងទៀតដូចគ្នា វិធីបែបនេះអាចប្រើបានតែក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាច្បាស់លាស់ឱ្យធ្វើតែប៉ុណ្ណោះ។ ពីព្រោះថា ការធ្វើបែបនេះនឹងធ្វើឱ្យនីតិវិធីនៃការផ្សះផ្សាមានភាពមិនច្បាស់លាស់ ហើយធ្វើឱ្យភាគីបាត់បង់ជំនឿទុកចិត្តលើតុលាការ ដោយសារតែភាគីម្ខាងមិនបានដឹងថា តើភាគីម្ខាងទៀតពិគ្រោះរឿងអ្វីខ្លះជាមួយតុលាការ។ វិធីសាស្ត្រដែលល្អ គឺតុលាការគួរតែធ្វើការផ្សះផ្សានៅចំពោះមុខភាគីទាំងសងខាងជាមួយគ្នាតែម្តង។

---

[33] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៤

[34] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៧

ប្រសិនបើការផ្សះផ្សា ធ្វើឡើងមិនទទួលបានលទ្ធផលនោះទេ តុលាការនឹងបន្តនីតិវិធីដោយបង្គាប់ឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍ (២.៣.២) ធ្វើការរៀបចំនឹងកំណត់ចំណុចវិវាទ (២.៣.៣) និងការរៀបចំភស្តុតាង (២.៣.៤) ដែលពាក់ព័ន្ធនឹងចំណុចវិវាទ ការរៀបចំជាមុនបែបនេះ គឺដើម្បីធ្វើឱ្យការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់បានរលូន និងមានភាពល្អិតល្អន់។[35]

### ២.៣.២ ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី

ក្នុងពេលធ្វើសេចក្តីថ្លែងការណ៍ ជាដំបូងតុលាការនឹងបង្គាប់ឱ្យភាគីដើមចោទធ្វើសេចក្តីថ្លែងការណ៍មុន (២.៣.២.១) ហើយបន្ទាប់ពីដើមចោទធ្វើសេចក្តីថ្លែងការណ៍ចប់ហើយ ទើបតុលាការបង្គាប់ឱ្យភាគីចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍តបវិញ (២.៣.២.២)។

#### ២.៣.២.១ សេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ

បន្ទាប់ពីធ្វើការផ្សះផ្សាមិនទទួលបានលទ្ធផល តុលាការបង្គាប់ឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងរបស់ខ្លួន ដោយសារតែ ក្រមនីតិវិធីរដ្ឋប្បវេណីជ្រើសយកគោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់ នោះការដែលគ្រាន់តែដាក់ពាក្យបណ្តឹងមិនអាចក្លាយជាឯកសារបានទេ ចាំបាច់ដើមចោទត្រូវតែធ្វើសេចក្តីថ្លែង-ការណ៍ដោយផ្ទាល់មាត់នៅកាលបរិច្ឆេទ ដោយត្រូវធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ជាសារធាតុអំពីខ្លឹមសារនានា។ ចំពោះសេចក្តីថ្លែងការណ៍អំពីការទាមទារ ដើមចោទត្រូវធ្វើឡើងក្រោមរូបភាពជា ការដាក់ពាក្យសុំលើអង្គសេចក្តី (ក) ចំណែកសេចក្តីថ្លែងការណ៍ ដែលគាំទ្រការទាមទារ ដើមចោទត្រូវធ្វើឡើងតាមរយៈការដាក់មធ្យោបាយតទល់ (ខ)។

##### ក. ការដាក់ពាក្យសុំលើអង្គសេចក្តី

ពាក្យសុំលើអង្គសេចក្តី ជាសកម្មភាពដែលភាគីដើមចោទទាមទារឱ្យតុលាការ ធ្វើសកម្មភាពជាក់លាក់ណាមួយ។ ចំពោះពាក្យសុំលើអង្គសេចក្តីរបស់ដើមចោទ គឺត្រូវធ្វើឡើងក្នុងរូបភាពជាសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹង និងអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ។

##### ខ. ការដាក់មធ្យោបាយតទល់

មធ្យោបាយតទល់ គឺជាការធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ដើមចោទ បន្ទាប់ពីដើមចោទបានដាក់ពាក្យសុំលើអង្គសេចក្តីនៃរឿងក្តី។ ក្នុងចំណោមមធ្យោបាយតទល់ ជាដំបូងដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍អះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាការទាមទារតាមផ្លូវបណ្តឹងសិន ប៉ុន្តែដោយសារ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយមិនអាចទទួលស្គាល់ដោយផ្ទាល់បាន ហេតុនេះតុលាការត្រូវប្រើវិធីសាស្ត្រ ធ្វើសេចក្តីសន្និដ្ឋានតាមភាពសមហេតុផល ដើម្បីកំណត់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនោះ។ ជាដំបូង តុលាការត្រូវកំណត់

[35] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៣

ថាសិទ្ធិនោះត្រូវបានគូភាគីទទួលស្គាល់ថាបង្កើតឡើងពីមុនមកឬទេ ហើយប្រសិនបើសិទ្ធិនោះបានបង្កើតឡើងមែន តើសិទ្ធិនោះត្រូវបានកំណត់ថារលត់ហើយឬនៅ។ ប្រសិនបើ សិទ្ធិនោះទទួលស្គាល់ថាបានបង្កើតឡើង តែមិនត្រូវបានទទួលស្គាល់ថារលត់នៅឡើយទេ សិទ្ធិនោះត្រូវបានវិនិច្ឆ័យថាមានអត្ថិភាពនាពេលបច្ចុប្បន្ន។ ដូច្នេះ ដើម្បីឱ្យតុលាការសម្រេចថា សិទ្ធិដែលជាខ្លឹមសារនៃការទាមទាររបស់ខ្លួនមានអត្ថិភាព ដើមចោទត្រូវធ្វើការអះអាងអង្គហេតុណាមួយដែលឆ្លើយតបទៅនឹងលក្ខខណ្ឌតាមផ្លូវច្បាប់ ដើម្បីឱ្យសិទ្ធនោះមានអានុភាពតាមផ្លូវច្បាប់។

### ២.៣.២.២ សេចក្តីថ្លែងការណ៍របស់ភាគីចុងចម្លើយ

ពេលដែលដើមចោទធ្វើសេចក្តីថ្លែងការណ៍រួច ចុងចម្លើយនឹងត្រូវធ្វើសេចក្តីថ្លែងការណ៍តប ដោយលើកឡើងនូវការទាមទារតាមរយៈការដាក់ពាក្យសុំលើអង្គសេចក្តី (ក) និងការដាក់មធ្យោបាយការពារខ្លួន (ខ) ផងដែរ។

#### ក. ការដាក់ពាក្យសុំលើអង្គសេចក្តី

ពាក្យសុំលើអង្គសេចក្តី ជាការដាក់ឯកសារទាមទាររបស់ចុងចម្លើយ ដែលសរសេរអំពីខ្លឹមសារនៃការទាមទារឱ្យទទួលស្គាល់ ច្រានចោល ឬលើកបណ្តឹងចោល។

ក្នុងករណីដែលចុងចម្លើយមិនបានដាក់ឯកសារចម្លើយទេ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវឱ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ពីការទាមទាររបស់ចុងចម្លើយតាមរយៈពាក្យសុំផ្ទាល់មាត់។ ប៉ុន្តែ ទោះជាចុងចម្លើយបានដាក់ឯកសារចម្លើយជាពាក្យសុំក្នុងរូបភាព ជាសេចក្តីថ្លែងការណ៍រួចហើយក៏ដោយ ភាគីចុងចម្លើយត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារ នៃការទាមទាររបស់ខ្លួន នៅក្នុងកាលបរិច្ឆេទនៃនីតិវិធី-ត្រៀមសម្រាប់ការទាញហេតុផល ដូចការធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងរបស់ដើមចោទដែរ ពីព្រោះការដែលចុងចម្លើយគ្រាន់តែដាក់ឯកសារចម្លើយជូនតុលាការនេះ មិនទាន់គ្រប់គ្រាន់ទេ។ ការធ្វើសេចក្តីថ្លែងការណ៍ក្នុងកាលបរិច្ឆេទនេះ ជាបឋមចុងចម្លើយត្រូវឆ្លើយចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានទាមទារ ដូចមាននៅក្នុងពាក្យបណ្តឹង។ ចម្លើយដែលភាគីចុងចម្លើយត្រូវឆ្លើយចំពោះសាលក្រមដែលដើមចោទទាមទារ មាន ០៣(បី)ប្រភេទ ដូចតទៅ៖

- ការទទួលស្គាល់ការទាមទារ។ ពេលដែលមានចុះអំពីការទទួលស្គាល់ការទាមទារក្នុងកំណត់ហេតុ កំណត់ហេតុនោះមានអានុភាពដូចគ្នានឹងសាលក្រមដែលចូលជាស្ថាពរដែរ។[36]
- ទាមទារឱ្យច្រានចោលនូវការទាមទារ ដោយអះអាងថាគ្មានមូលហេតុនៃការទាមទារ។
- ទាមទារឱ្យលើកបណ្តឹងចោល ដោយសារពុំមានលក្ខខណ្ឌបណ្តឹង។

#### ខ. ការដាក់មធ្យោបាយការពារខ្លួន

[36] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២២

មធ្យោបាយការពារខ្លួន គឺជាការធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួន ដែលចុងចម្លើយត្រូវធ្វើនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

ក្នុងចម្លើយចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ករណីដែលចុងចម្លើយទាមទារឱ្យច្រានចោលនូវការទាមទាររបស់ដើមចោទ តុលាការត្រូវឱ្យចុងចម្លើយធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារ តទៅទៀត។ ក្នុងការឆ្លើយតបទៅនឹងការអះអាងរបស់ដើមចោទ ចុងចម្លើយអាចនឹងធ្វើវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារ តាមរយៈការបង្ហាញមធ្យោបាយការពារខ្លួន ដែលជាអង្គហេតុតវ៉ា ឬគេហៅថា ការតវ៉ា។ ការតវ៉ា ជាអង្គហេតុដែលអះអាងដោយចុងចម្លើយ ដើម្បីបង្កើតជាឧបសគ្គនៃការកកើតសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ឬការរំលត់សិទ្ធិដែលកើតឡើងម្តងរួចហើយ ឬការរារាំងនូវការអនុវត្តសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលអះអាងដោយដើមចោទ។ ការតវ៉ានេះ អាចគិតថាជាការអះអាងចម្បងរបស់ចុងចម្លើយ ។

### ២.៣.៣ ការរៀបចំ និងកំណត់ចំណុចវិវាទ

បន្ទាប់ពីភាគីបានធ្វើសេចក្តីថ្លែងការណ៍រួចរាល់ហើយ តុលាការត្រូវធ្វើការរៀបចំនិងកំណត់ចំណុចវិវាទ ដោយត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី ជាមុនសិន (២.៣.៣.១) បន្ទាប់មកទៀតទើបធ្វើការកំណត់ចំណុចវិវាទ (២.៣.៣.២)។

#### ២.៣.៣.១ ការរៀបចំការអះអាងរបស់ភាគី

កម្មវត្ថុនៃបណ្តឹង ជាសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលភាគីដើមចោទបានអះអាងក្នុងការទាមទារតាមផ្លូវបណ្តឹង។ ប៉ុន្តែ ដើម្បីអាចឱ្យតុលាការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តបាន ត្រូវតែមានការបំភ្លឺរបស់ភាគីអំពីទំនាក់ទំនងអង្គហេតុនៃរឿងក្តី ដោយតុលាការត្រូវរៀបចំការអះអាងរបស់ ភាគីឱ្យបានត្រឹមត្រូវ។ នៅពេលដើមចោទធ្វើការអះអាងនូវអង្គហេតុទាំងឡាយដែលគាំទ្រពាក្យបណ្តឹងរបស់ខ្លួនចប់ ចុងចម្លើយអាចធ្វើការ ឬមិនទទួលស្គាល់អង្គហេតុនោះ ហើយចុងចម្លើយ ក៏អាចលើកឡើងនូវអង្គហេតុតវ៉ាទៅលើការទាមទាររបស់ដើមចោទផងដែរ។ ហេតុនេះ ការអះអាងរបស់ភាគីទាំងពីរ គឺមានអង្គហេតុច្រើន ដែលនាំឱ្យតុលាការត្រូវស្នើឱ្យភាគីដកការអះអាងអំពីអង្គហេតុ ដែលមិនមានផលប្រយោជន៍ដល់ការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តជាកម្មវត្ថុនៃបណ្តឹង និងផាត់ចោលនូវអង្គហេតុទាំងឡាយដែលភាគីអះអាងដូចគ្នា។ ចំណែកការអះអាងដែលអាចឱ្យតុលាការសម្រេចអំពីអត្ថិភាព ឬនត្ថិភាព នៃសិទ្ធិជាកម្មវត្ថុនៃបណ្តឹង តុលាការនឹងរៀបចំការអះអាងនោះ ហើយឱ្យភាគីម្ខាងទៀតធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់។ ក្នុងករណីដែលភាគីម្ខាងបានអះអាងអំពីអត្ថិភាពនៃអង្គហេតុណាមួយ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ បានបែងចែកអាកប្បកិរិយារបស់ភាគីម្ខាងទៀតជា០៤បែប ដូចខាងក្រោម៖

- ភាគីម្ខាងទៀតបានធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុនោះ ជាអាកប្បកិរិយាបដិសេធ ឬមិនទទួលស្គាល់។
- ភាគីម្ខាងទៀតបានធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុនោះ ជាអាកប្បកិរិយាសារភាព ឬទទួលស្គាល់។
- ភាគីម្ខាងទៀតបានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនបានដឹងអំពីអត្ថិភាពនៃអង្គហេតុនោះទេ ជាអាកប្បកិរិយា មិនបានដឹង។
- ភាគីម្ខាងទៀត មិនឆ្លើយអ្វីទាំងអស់។

ដើម្បីឱ្យការទទួលស្គាល់ ឬមិនទទួលស្គាល់នេះ មានអានុភាពបាន សំខាន់មិនត្រូវមើលតែឯកសារ ដូចជាឯកសារចម្លើយរបស់ភាគី ជាអាទិ៍ទេ ចាំបាច់ត្រូវក្តាប់ឱ្យបាននូវចិត្តគំនិតរបស់ភាគី។ ពេលដែលការអះអាងរបស់ដើមចោទ ឬការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយមានភាពមិនច្បាស់លាស់ តុលាការត្រូវទាមទារឱ្យបំភ្លឺ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់។

### ២.៣.៣.២ ការកំណត់ចំណុចវិវាទ

ចំណុចវិវាទ ជាចំណុចទាំងឡាយដែលភាគីប្រកែកគ្នា។ ហេតុនេះក្នុងការកំណត់ចំណុចវិវាទ តុលាការត្រូវពិចារណាអាកប្បកិរិយារបស់ភាគី។ អង្គហេតុដែលភាគីបដិសេធ (មិនទទួលស្គាល់) នោះជាចំណុចវិវាទ ប៉ុន្តែបើអង្គហេតុនោះត្រូវបានភាគីសារភាព(ទទួលស្គាល់) វាមិនមែនជាចំណុចវិវាទទេ។ បញ្ហានឹងត្រូវមាននៅពេលដែលភាគីឆ្លើយថា ខ្លួនមិនបានដឹង និងករណីដែលភាគីមិនឆ្លើយអ្វីទាំងអស់។ ចំពោះសេចក្តីថ្លែងការដែលភាគីឆ្លើយថា មិនបានដឹង ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ សន្មតថាអាកប្បកិរិយានោះ ជាការតវ៉ាចំពោះអង្គហេតុដែលវានឹងក្លាយជាចំណុចវិវាទ។[37] រីឯ ករណីដែលភាគី នៅស្ងៀមមិនឆ្លើយអ្វីទាំងអស់ ត្រូវចាត់ទុកថាភាគីបានសារភាពអំពីអង្គហេតុនោះ លើកលែងតែតុលាការយល់ឃើញថាអាកប្បកិរិយាទាំងស្រុងរបស់ភាគីនោះ បានតវ៉ាចំពោះអង្គហេតុនោះ ។[38] ដោយសារការមិនឆ្លើយរបស់ភាគី ត្រូវបានចាត់ទុកថាជាការសារភាព ឬទទួលស្គាល់ ទើបអង្គហេតុនោះមិនក្លាយជាចំណុចវិវាទ ។

ក្នុងការកំណត់ចំណុចវិវាទ តុលាការត្រូវស្វែងរកប្រភពពិតប្រាកដនៃវិវាទ ដោយត្រូវស្វែងរកចំណុចស្នូលនៃអង្គហេតុដែលមានវិវាទ ទើបអាចឆ្លើយតបទៅនឹងការកំណត់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តតាមច្បាប់សារធាតុ ។ មានន័យថា ពេលដែលចំណុចវិវាទត្រូវបានដោះស្រាយរួច នោះតុលាការអាចសម្រេចដោយចេញសាលក្រមដើម្បីបញ្ចប់រឿងក្តីបាន ។

[37] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៦

[38] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៣

ក្នុងការកំណត់ចំណុចវិវាទ តុលាការអាចប្រើជាប្រយោគសំណួរ ឬជាប្រយោគធម្មតា ។

### ២.៣.៤ ការរៀបចំភស្តុតាង

ភាពចាំបាច់ដែលត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង ឬអត់ អាស្រ័យទៅតាមអាកប្បកិរិយាទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគី។ ដូច្នេះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ តើត្រូវពិនិត្យភស្តុតាងទៅលើអង្គហេតុណាមួយ នោះចម្លើយទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគីពិតជាសំខាន់ណាស់។ ហើយអង្គហេតុដែលមានវិវាទ ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង ។

ភស្តុតាងត្រូវបញ្ជាក់ចែកជា៥ (ប្រាំ) ប្រភេទ គឺ៖

- ការសាកសួរសាមីភាគី
- ការសាកសួរសាក្សី
- ការធ្វើកោសលវិច័យ
- ភស្តុតាងជាឯកសារ
- និងការត្រួតពិនិត្យ។

ដើម្បីអាចឱ្យតុលាការធ្វើការពិនិត្យភស្តុតាង នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន ចាំបាច់ត្រូវធ្វើការរៀបចំភស្តុតាងនៅក្នុងនិតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាមុនសិន។ ប៉ុន្តែការរៀបចំភស្តុតាងនេះ តុលាការមិនអាចបង្គាប់ឱ្យភាគីដាក់ភស្តុតាងណាមួយទៅតាមការយល់ឃើញនោះឡើយ។ បានន័យថា ភាគីដែលមានបំណងឱ្យតុលាការធ្វើការពិនិត្យភស្តុតាងរបស់ខ្លួន គឺត្រូវស្នើសុំមកតុលាការ (២.៣.៤.១) ជាមុន ទើបតុលាការធ្វើការសម្រេចទៅតាមការស្នើសុំនោះ (២.៣.៤.២) ។

#### ២.៣.៤.១ ការស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង

ភាគីដែលបានស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង ត្រូវកំណត់ឱ្យបានជាក់លាក់នូវអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ ហើយគប្បីបំភ្លឺឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និងទំនាក់ទំនងរវាងអង្គហេតុ និងភស្តុតាង។ ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយការផ្តល់ឯកសារដែលសាមីភាគីមាន ឬដាក់ពាក្យស្នើសុំទៅតុលាការ ដើម្បីតុលាការបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់ឯកសារនោះ។ ភាគីដែលបានស្នើសុំពិនិត្យភស្តុតាងជាឯកសារ ត្រូវបញ្ជាក់ថា ឯកសារនោះធ្វើឡើងដោយត្រឹមត្រូវ។ ចំពោះឯកសារឯកជនដែលសន្មតថាធ្វើឡើងដោយត្រឹមត្រូវ ជាឯកសារដែលមានចុះហត្ថលេខាសាមីភាគី ឬអ្នកតំណាង។

#### ២.៣.៤.២ ការសម្រេចទៅលើភស្តុតាង

តុលាការត្រូវសម្រេចទទួលយក ឬមិនទទួលយកនូវការស្នើសុំពិនិត្យភស្តុតាងរបស់ភាគី តាមរយៈដីកាសម្រេច។ ការចេញដីកាសម្រេច ខុសពីសាលក្រម ដោយដីកាសម្រេចមិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរក៏បាន

ដែរ ឱ្យតែបានជូនដំណឹងដល់ភាគីតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ។ បានន័យថា ការចេញដីកាសម្រេច ធ្វើជាលាយលក្ខណ៍អក្សរក៏បាន ឬជូនដំណឹងដោយផ្ទាល់មាត់អំពីការសម្រេចក្នុងកាលបរិច្ឆេទក៏បាន។ ក្នុងករណីដែលបានជូនដំណឹងអំពីដីកាសម្រេច ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីជូនដំណឹង ដាក់ក្នុងសំណុំរឿង។

ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចធ្វើការពិនិត្យភស្តុតាងជាឯកសារក្នុងពេលកំណត់ណាមួយបាន ដោយមានការកម្រិតជាចាំបាច់ដើម្បីធ្វើការរៀបចំចំណុចវិវាទនៃរឿងក្តី និងរៀបចំភស្តុតាងប៉ុណ្ណោះ។[39] ចំពោះភស្តុតាង ០៤ ប្រភេទទៀត គឺតុលាការត្រូវទុកទៅពិនិត្យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ពេលពិនិត្យភស្តុតាងជាឯកសារ តុលាការត្រូវមើល និងអានសំណៅឯកសារដើមនៃឯកសារដែលភាគីបានដាក់ឱ្យ។ ក្រោយពេលតុលាការពិនិត្យភស្តុតាងហើយ ជាធម្មតាត្រូវសងសំណៅដើមឱ្យភាគីវិញ ហើយបញ្ចូលឯកសារចម្លងទៅក្នុងសំណុំរឿង ប៉ុន្តែ បើយល់ឃើញថាចាំបាច់តុលាការអាចឃាត់ទុកឯកសារនោះបាន។

## ២.៣.៤.៣ កំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានសកម្មភាពច្រើនដែលត្រូវបានធ្វើដោយចៅក្រម ភាគី ឬអ្នកតំណាង ហើយសកម្មភាពនេះមិនអាចបញ្ជាក់បានទេ ប្រសិនបើពុំមានការកត់ត្រា។ មួយវិញទៀត កំណត់ហេតុនេះមានសារៈសំខាន់ណាស់សម្រាប់តុលាការជាន់ខ្ពស់ក្នុងការពិនិត្យលើចំណាត់ការរបស់តុលាការដែលបានធ្វើកំណត់ហេតុនោះ។

### ក. អ្នកធ្វើកំណត់ហេតុ

មួយវិញទៀត កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅក្នុងកាលបរិច្ឆេទនីមួយៗ[40] ដូចនេះអ្នកដែលមានតួនាទីធ្វើកំណត់ហេតុ គឺក្រឡាបញ្ជីដែលជាអ្នកមានសមត្ថកិច្ច។

### ខ. ទម្រង់កំណត់ហេតុ

ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ។[41] នៅក្នុងកំណត់ហេតុ ត្រូវមានចំណុចដូចខាងក្រោមៈ

- ចំណុចជារូបមន្ត

---

[39] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៦

[40] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៩

[41] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៩

- សញ្ញាណរឿងក្តី
- ឈ្មោះចៅក្រម និងក្រឡាបញ្ជី
- ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន
- ពេលវេលា និងទីកន្លែង។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុ។[42]

- ចំណុចជាសារធាតុ

ក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស គឺត្រូវកត់ត្រាឱ្យច្បាស់នូវចំនុចដូចខាងក្រោម៖

- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារ។
- ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង
- ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគីចំពោះអង្គហេតុដែលបានអះអាងដោយ ភាគីម្ខាងទៀត និងការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ ។
- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់ការទាមទារ។
- ចំណុចដែលតុលាការបង្គាប់ឱ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី
- ការសម្រេចសេចក្តីដែលធ្វើឡើងនៅក្នុងកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយលក្ខណ៍អក្សរ (ការចេញដីកាសម្រេចដោយផ្ទាល់មាត់)។

**នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចមានសកម្មភាពផ្សេងៗកើតឡើងដូចជា៖**

- ការបំបែក ឬការបញ្ចូលរឿងក្តី[43]
- ការបន្ថែម និងការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង[44]
- ការធ្វើបណ្តឹងតប[45]

---

[42] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១០
[43] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១១
[44] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៩
[45] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨៤

- ការតវ៉ាចំពោះការដឹកនាំនីតិវិធី[46]
- ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុ ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍[47]
- ការសុំដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ[48]
- ការស្នើសុំដីកាសម្រេចឱ្យផ្តល់ឯកសារ
- ការធ្វើសកម្មភាពផ្សេងទៀត
- បណ្តឹងជិតចិត្តចៅក្រម[49] ។

[46] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩១

[47] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១២

[48] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧

[49] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨

# ជំពូកទី៣
# ការបញ្ចប់នីតិវិធីត្រៀមសម្រាប់
# ការទាញហេតុផល

# ជំពូកទី៣

# ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានចាប់ផ្ដើមឡើង និងប្រព្រឹត្តទៅរហូតមកដល់ពេលនេះ ក៏ត្រូវបានបញ្ចប់ផងដែរ។ ប៉ុន្តែ សួរថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនឹងត្រូវបញ្ចប់នៅពេលណា? (៣.១) ហើយពេលបញ្ចប់នីតិវិធីត្រៀមតុលាការត្រូវបំពេញសកម្មភាពអ្វីខ្លះ? (៣.២) និងវាបង្កើតអានុភាពអ្វីខ្លះនៅពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុបានបញ្ចប់ (៣.៣)។

## ៣.១ ពេលវេលាដែលត្រូវបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ពេលវេលានៃការបញ្ចប់ គឺប្រែប្រួលទៅតាមគោលបំណង នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ មានន័យថា នៅពេលគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបំពេញ នោះនីតិវិធីនឹងត្រូវបញ្ចប់ (៣.១.១) ប៉ុន្តែ មានករណីខ្លះទោះជាគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់បំពេញក៏ដោយ ក៏នីតិវិធីត្រូវតែបញ្ចប់ដែរ (៣.១.២)។

### ៣.១.១ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបំពេញ

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបង្កើតឡើង ដើម្បីធ្វើឱ្យមានភាពងាយស្រួល និងឆាប់រហ័សដល់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ តាមរយៈការរៀបចំនឹងកំណត់ចំណុចវិវាទ និងការរៀបចំភស្តុតាងឱ្យបានច្បាស់លាស់។ នៅពេលដែលការរៀបចំនឹងកំណត់ចំណុចវិវាទ និងការរៀបចំភស្តុតាង កំណត់បានជាក់លាក់ហើយ នីតិវិធីត្រៀមសម្រាប់ការទាញហេតុនឹងត្រូវបញ្ចប់។ ចំណែកឯ ការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុន្មានលើកនោះ ច្បាប់មិនបានកំណត់ទេ សំខាន់ឱ្យតែតុលាការអាចបំពេញគោលបំណងនៃនីតិវិធី គឺការរៀបចំនឹងកំណត់ចំនុចវិវាទ និងការរៀបចំភស្តុតាង បានជាក់លាក់។

### ៣.១.២ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់បំពេញ

មានករណីមួយចំនួន ទោះជាគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់បំពេញក៏ដោយ ក៏នីតិវិធីត្រៀមត្រូវបញ្ចប់ដែរ ដូចជា៖

- អវត្តមានរបស់ភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ករណីភាគីអវត្តមាន នោះនឹងធ្វើឱ្យនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបញ្ចប់ ទោះជាការអវត្តមាននោះ គឺអវត្តមានភាគីម្ខាង ឬអវត្តមានភាគីទាំងសងខាងក៏ដោយ។

- **ករណីអវត្តមានភាគីម្ខាង**

ក្នុងនីតិវិធីត្រៀម ពេលមានភាគីម្ខាងអវត្តមាន ភាគីនោះអាចជាភាគីដើមចោទ ហើយពេលខ្លះអាចជាភាគីចុងចម្លើយផងដែរ។

**ក.ករណីអវត្តមានភាគីដើមចោទ**

ប្រសិនបើដើមចោទអវត្តមាន ឬមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម-សម្រាប់ការទាញហេតុផលទេ តុលាការត្រូវសម្រេចច្រានចោលការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំងមុខ។[50] ដោយសារ ភាគីដើមចោទជាបុគ្គលដែលដាក់ពាក្យបណ្ដឹងមកតុលាការដើម្បីទាមទារឱ្យតុលាការសម្រេចពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរបស់ខ្លួន តែបើដើមចោទមិនបង្ហាញខ្លួនទេ បាននន័យថាដើមចោទគ្មានឆន្ទៈក្នុងការទាមទារតាមនីតិវិធីនៃបណ្ដឹងនោះទេ ដូច្នេះតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទ។

**ខ. ករណីអវត្តមានភាគីចុងចម្លើយ**

ប្រសិនបើភាគីចុងចម្លើយអវត្តមាន ឬមិនបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម-សម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ចប់នីតិវិធីត្រៀមភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់។[51] ត្រង់ចំណុចនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខ ដូចករណីដើមអវត្តមាននោះទេ ពីព្រោះថា ចុងចម្លើយមិនបានចូលរួមក្នុងនីតិវិធីត្រៀម អាចមានករណីដែលការទាមទាររបស់ដើមចោទមិនសមហេតុផល ដូច្នេះ ទាមទារឱ្យមានការទាញហេតុផលដោយផ្ទាល់មាត់។ ម្យ៉ាងទៀត តុលាការក៏មិនអាចចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បានទេ ហេតុដូច្នេះ តុលាការត្រូវតែកំណត់កាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ ។

- **ករណីអវត្តមានភាគីទាំងសងខាង**

ករណីដែលភាគីទាំងសងខាងអវត្តមាន ឬមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀម-សម្រាប់ការទាញហេតុផលលើកដំបូង ហើយមិនបានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីក្នុងអំឡុងពេល១(មួយ)ខែ នោះត្រូវចាត់ទុកថា ភាគីដើមចោទបានដកពាក្យបណ្ដឹង។ ហើយក៏ត្រូវចាត់ទុកថា បានដកពាក្យបណ្ដឹងផងដែរ ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាល-

[50] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០០ កថាខណ្ឌទី១

[51] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០១ កថាខណ្ឌទី១

បរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ២(ពីរ)ដង ជាប់គ្នា។[52] ការចាត់ទុកដូច្នេះ គឺដោយសារតែភាគីទាំងសងខាងគ្មានបំណងទាមទារសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត តាមនីតិវិធីបណ្ដឹងនោះទេ។

- ការផ្សះផ្សាទទួលបានជោគជ័យ

ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចធ្វើការផ្សះផ្សាបាន។[53] ក្នុងការផ្សះផ្សាលទ្ធផលដែលអាចទទួលបានមានដូចជា ការដកពាក្យបណ្ដឹង ការសះជា ការទទួលស្គាល់ការទាមទារ និងការលះបង់ការទាមទារ។ ករណីមានការដកពាក្យបណ្ដឹងនោះនឹងធ្វើឱ្យពាក្យត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង។[54] ចំណែកឯ ការសះជា ការលះបង់នូវការទាមទារ និងការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅកំណត់ហេតុ ហើយកំណត់ហេតុនេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ។[55]

- ការបញ្ចប់បណ្ដឹងដោយសារភាគីទទួលមរណភាព ឬការរួមបញ្ចូលគ្នានៃនីតិបុគ្គល

ក្នុងករណីដែលភាគីបានទទួលមរណភាព ឬបានរលត់ដោយការរួមបញ្ចូលគ្នានៃនីតិបុគ្គលហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹង ឬសិទ្ធិ ឬកាតព្វកិច្ចនោះបានធ្លាក់ទៅលើបុគ្គលតែម្នាក់ នោះនីតិវិធីនៃបណ្ដឹងត្រូវបានបញ្ចប់។ ក្នុងករណីនេះ តុលាការត្រូវចេញសាលក្រមប្រកាសបញ្ចប់បណ្ដឹងនោះ។[56]

## ៣.២ សកម្មភាពដែលត្រូវបំពេញនៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុត្រូវបានបញ្ចប់ តុលាការត្រូវបញ្ជាក់ពីអង្គហេតុដែលត្រូវបំភ្លឺជាមួយភាគី (៣.២.១) បន្ទាប់មកត្រូវធ្វើការកំណត់កាលបរិច្ឆេទលើកទី១ នៅនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ (៣.២.២) តែម្ដង។

### ៣.២.១ ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ

ពេលបានរៀបចំចំណុចវិវាទរួចរាល់ហើយ មុនបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបញ្ជាក់ជាមួយភាគី អំពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺតាមរយៈការពិនិត្យភស្តុតាង នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។[57] បានន័យថា ភាគីត្រូវធ្វើការបញ្ជាក់ថាអង្គហេតុណាខ្លះជាចំណុចវិវាទ ដែល

[52] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២១៩

[53] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៧

[54] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២១៨ កថាខណ្ឌទី១

[55] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២២

[56] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៧៤

[57] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៧

ត្រូវជាកម្មវត្ថុនៃការពិនិត្យភស្តុតាងដោយការទទួលស្គាល់រួមគ្នារវាងភាគី និងតុលាការ ហើយចាំបាច់ត្រូវតែធ្វើការបញ្ជាក់ដោយខានពុំបាន តាមរយៈការពិនិត្យភស្តុតាងជាសមូហវិធី នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។

### ៣.២.២ ការកំណត់កាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើកទី១

ពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទលើកទី១ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម។[58]

ការកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធានាថា គូភាគីអាចមានវត្តមានបាន ជាការគោរពនូវគោលការណ៍ចំពោះមុខ។[59] តុលាការត្រូវកំណត់កាលបរិច្ឆេទតាមពាក្យសុំ ឬកំណត់ដោយឆន្ទានុសិទ្ធិ។ ការផ្លាស់ប្តូរកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់មិនត្រូវបានអនុញ្ញាតទេ លើកលែងតែករណីដែលមានមូលហេតុមិនអាចជៀសវាងបាន។

ចំពោះការកោះហៅឱ្យគូភាគីចូលរួមតាមកាលបរិច្ឆេទ តុលាការអាចធ្វើតាមរយៈការជូនដំណឹង ឬដោយបញ្ជូនដីកាកោះក៏បាន។[60]

## ៣.៣ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ហើយ គឺហាមមិនឱ្យភាគីដាក់មធ្យោបាយតទល់ឬការពារខ្លួនបាទទៀតទេ។ បើភាគីនូវតែដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួនមកកាន់តុលាការទៀត តុលាការនឹងធ្វើការលើកចោលនូវមធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួននោះ (៣.២.១) ប៉ុន្តែ មានករណីលើកលែងមួយចំនួន (៣.២.២) ផងដែរ។[61]

### ៣.៣.១. ការលើកចោលមធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួន

ក្រោយពីបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួនថ្មីបានទៀតទេ។ បើអនុញ្ញាតឱ្យគូភាគីដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅក្រោយការបញ្ចប់នីតិវិធីត្រៀម នឹងធ្វើឱ្យចំណុចវិវាទដែលបានកំណត់រួចរាល់តាមរយៈការរៀបចំការអះអាងរបស់គូភាគី និងការរៀបចំភស្តុតាងទុកពិនិត្យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់គ្មានខ្លឹមសារ ហើយធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង។

[58] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៣

[59] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៥ កថាខណ្ឌទី១

[60] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៤២

[61] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៨

### ៣.៣.២ ករណីលើកលែង

ករណីដែលតុលាការសម្រេចទទួលយកមធ្យោបាយតទល់ ឬការពារខ្លួន រួមមាន៖

- មធ្យោបាយដែលទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ។ ឧទាហរណ៍៖ ការបញ្ជាក់អំពី អត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចតុលាការ និងអត្ថិភាព ឬនត្ថិភាពនៃមូលហេតុដកហូតសមត្ថកិច្ចជំនុំជម្រះក្តី ជាអាទិ៍។

- មធ្យោបាយ ដែលមិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង។ ឧទាហរណ៍៖ ភាគីស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង ដែលអាចពិនិត្យភ្លាមៗបាន ដូចជា ឯកសារដែលភាគីដាក់តាមខ្លួនមក ឬសាក្សីដែលភាគីនាំមកជាមួយ ក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តែម្តង ។

- ករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ នៅមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ដោយគ្មានកំហុស ។ ឧទាហរណ៍ ភាគីបានអះអាងអង្គហេតុដែលកើតឡើង នៅក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬករណីដែល ភាគីស្នើសុំឱ្យតុលាការពិនិត្យភស្តុតាងដែលទើបនឹងរកឃើញ ជាអាទិ៍ ។

តុលាការនឹងធ្វើការសម្រេចទទួលយកនូវមធ្យោបាយតទល់ ឬការពារខ្លួនតាមរយៈដីកាសម្រេច។ ក្នុងករណី ភាគីបានដាក់មធ្យោបាយតទល់ ឬការពារខ្លួន នៅមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការនឹងធ្វើដីកាសម្រេចជាលាយលក្ខណ៍អក្សរ ហើយជូនដំណឹងអំពីដីកាសម្រេចនេះទៅកាន់ភាគី។ នៅក្នុងការជូនដំណឹងអំពីដីកាសម្រេច តុលាការនឹងបង្គាប់ឱ្យក្រឡាបញ្ជី ចាត់ចែងធ្វើដីកាបញ្ជូននេះ ដើម្បីបានរបាយការណ៍ស្តីពីការបញ្ជូន ដាក់ចូលក្នុងសំណុំរឿង។ ប៉ុន្តែប្រសិនបើភាគីបានដាក់មធ្យោបាយតទល់ ឬការពារខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់តុលាការនឹងចេញដីកាសម្រេចដោយផ្ទាល់មាត់ ហើយជូនដំណឹងទៅកាន់ភាគី នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នោះតែម្តង។

❖ **អញ្ញត្រកម្ម**

នៅពេលតុលាកាធ្វើការផ្សះផ្សាអាចទទួលបានលទ្ធផលមានដូចជា៖

- ការដកពាក្យបណ្តឹង គឺជាសកម្មភាពដកមួយភាគ ឬច្រើន ឬទាំងស្រុងនូវពាក្យសុំទាមទារឱ្យចេញសាលក្រមតាមរយៈបណ្តឹងដោយដើមចោទ។ ការដកពាក្យបណ្តឹង ជាគោលការណ៍ត្រូវ ធ្វើជាលាយលក្ខណ៍អក្សរ។[62] ប៉ុន្តែការដកពាក្យបណ្តឹងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចដកពាក្យបណ្តឹង

[62] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី១

ដោយផ្ទាល់មាត់បាន។[63] ករណីមានការដកពាក្យបណ្តឹងនោះនឹងធ្វើឱ្យពាក្យបណ្តឹង ត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង។[64]

- ការទទួលស្គាល់នូវការទាមទារ គឺជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងរបស់ដើមចោទដែលទទួលស្គាល់ឯងថា ការទាមទារតាមផ្លូវបណ្តឹងរបស់ខ្លួន ពុំមានភាពត្រឹមត្រូវ។ ការទទួលស្គាល់នូវការទាមទារ ត្រូវចុះក្នុងកំណត់ហេតុដែលមានអានុភាព ដូចសាលក្រមស្ថាពរ។
- ការលះបង់នូវការទាមទារ គឺជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងរបស់ចុងចម្លើយដែលទទួលស្គាល់ដោយគ្មានលក្ខខណ្ឌថា ការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទមានមូលហេតុត្រឹមត្រូវ។ ការលះបង់នូវការទាមទារ ត្រូវចុះក្នុងកំណត់ហេតុដែលមានអានុភាព ដូចសាលក្រមស្ថាពរ។
- ការសះជា គឺសំដៅទៅលើកិច្ចសន្យាមួយដែលភាគីបានព្រមព្រៀងបញ្ចប់វិវាទដែលមានរវាងគ្នា និងគ្នាសោយសម្បទានទៅវិញទៅមក។ ការសះជា គឺធ្វើឡើងតាមរយៈកំណត់ហេតុសះជា ដែលមានអានុភាពដូចសាលក្រមស្ថាពរ។

ជារួមមក ការសះជា ការលះបង់នូវការទាមទារ និងការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅកំណត់ហេតុ ហើយកំណត់ហេតុនេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ។[65]

[63] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី២

[64] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២១៨ កថាខណ្ឌទី១

[65] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២២

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវលើប្រធានបទស្តីពី «នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល» គឺតុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្រប និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យ បានល្អិតល្អន់។ បន្ទាប់ពីបានធ្វើការបកស្រាយដូចខាងលើ សង្កេតឃើញថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដ៏សំខាន់ ដែលមិនអាចខ្វះបាននៅក្នុងនីតិវិធីនៃបណ្តឹង ពីព្រោះថា នីតិវិធីនេះបានជួយសម្រួលដល់ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឱ្យដំណើរការទៅបានយ៉ាងរលូន និងមានភាពច្បាស់លាស់នៅក្នុងកិច្ចដំណើរការនីតិវិធី។ម្យ៉ាងវិញទៀត ចំពោះការដាក់មធ្យោបាយតទល់ ឬការពារខ្លួនដោយចេតនាទុច្ចរិត ឬមិនស្មោះត្រង់របស់ភាគី នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឡើយ។ បញ្ហានេះតែងតែកើតមានឡើងជាញឹកញាប់ ដែលភាគីណាមួយឆ្លៀតឱកាសដោយមិនគោរពនៅគោលការណ៍ស្មោះត្រង់ដែលតុលាការបានព្រមទទួលយកនូវសកម្មភាពទាំងនោះ ហើយបានបង្កឱ្យមានភាពខូចខាតធ្ងន់ធ្ងរទៅលើភាគីម្ខាងទៀត។ សកម្មភាពទាំងនោះបានបង្កឱ្យភាគីម្ខាងទៀតមិនអាចមានឱកាសសម្រាប់ការពារខ្លួន ឬតទល់ ហើយទោះបីជាយ៉ាងនេះក្តី ក៏សិទ្ធិនៃការដាក់មធ្យោបាយតទល់ ឬការពារខ្លួនត្រូវបានទទួលស្គាល់ចំពោះភាគីដៃ លសុចរិត ក្នុងករណីដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ក៏ដោយ។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ជាមូលដ្ឋានដែលឱ្យតុលាការចេញសាលក្រមឱ្យឆ្លើយតបជាមួយនឹងការអះអាងរបស់ភាគីផងដែរ។ ប្រសិនបើ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដំណើរការដោយមិនមានភាពច្បាស់លាស់ទេ តុលាការក៏មិនអាចបន្តនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយធ្វើការពិនិត្យភស្តុតាងជាសមូហវិធី ហើយត្រូវបង្វិលនីតិវិធីត្រឡប់ទៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឡើងវិញដើម្បីផ្តល់យុត្តិធម៌ជូនភាគី ហើយក៏ជាមូលហេតុដែលនាំឱ្យនីតិវិធីយឺតយ៉ាវផងដែរ។ ដូច្នេះហើយដើម្បីជៀសវាងការអូសបន្លាយពេលវេលា និងការផ្តល់យុត្តិធម៌ជូនភាគីមានការយឺតយ៉ាវ គឺទាមទារឱ្យតុលាការត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីស្វែងរកចំណុចស្នូលនៃវិវាទ។

ជាការពិតណាស់ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានដឹកនាំដោយតុលាការ ចំណែកគូភាគីជាអ្នកធ្វើសកម្មភាពទៅតាមការបង្គាប់ ឬការអនុញ្ញាតរបស់តុលាការ។ ប៉ុន្តែ ក្នុងដំណើរការនីតិវិធី គូភាគីដែលមានវិវាទនឹងគ្នា តែងតែធ្វើសកម្មភាពផ្សេងៗ ដើម្បីប្រយោជន៍រៀងៗខ្លួន ជាហេតុនាំឱ្យតុលាការពិបាកក្នុងការដឹកនាំចាត់ចែង និងគ្រប់គ្រងនីតិវិធីឱ្យប្រព្រឹត្តទៅដោយរលូន មានភាពច្បាស់លាស់ និងមានប្រសិទ្ធភាពណាស់។ ហេតុនេះហើយ ត្រូវទាមទារឱ្យតុលាការមានចំណេះដឹង និងបទពិសោធន៍ ដើម្បីឱ្យនីតិវិធីត្រៀមសម្រាប់ការ

ទាញហេតុផលប្រព្រឹត្តទៅបានល្អ ហើយចៅក្រមក៏ត្រូវរក្សាទំនាក់ទំនងល្អជាមួយចៅក្រមដទៃទៀតផងដែរ នៅពេលជួបប្រទះបញ្ហាក្នុងកិច្ចនីតិវិធី និងអាចផ្លាស់ប្តូរយោបល់គ្នា តាមរយៈការផ្លាស់ប្តូរមតិទៅវិញទៅមកដើម្បីស្វែងដំណោះស្រាយ។

សរុបសេចក្តីមក នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលបានយកមកបកស្រាយខាងលើនេះ ទោះបីជាមិនបានបកស្រាយបានគ្រប់ជ្រុងជ្រោយ តែនាងខ្ញុំសង្ឃឹមថាការបកស្រាយមួយនេះនឹងអាចមានសារៈប្រយោជន៍នៅពេលដែលជួបបញ្ហានៅក្នុង ដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ និងអាចជាពន្លឺសម្រាប់ជំនួយដល់ស្មារតីផងដែរ។

# អនុសាសន៍

បច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ យើងឃើញថា ជម្លោះនៅក្នុងរឿងក្ដីរដ្ឋប្បវេណីកើតមានច្រើនជាបន្តបន្ទាប់ ទាំងរឿងអង្គសេចក្ដី និងរឿងមិនមែនអង្គសេចក្ដី។ នៅក្នុងរឿងក្ដីអង្គសេចក្ដី ដែលតម្រូវឱ្យមានភាពឆាប់រហ័ស ដើម្បីធ្វើការសម្រេចសេចក្ដីដោយគ្មានភាពយឺតយ៉ាវ ដែលមិនធ្វើឱ្យមានការបាត់បង់នូវផលប្រយោជន៍របស់ភាគីនៃរឿងក្ដី។ ថ្វីត្បិតតែនៅក្នុងទ្រឹស្ដីមិនមានជួបបញ្ហា ប៉ុន្តែការអនុវត្តជាក់ស្ដែង ជួបប្រទះនូវបញ្ហាមួយចំនួនផងដែរ។ ដើម្បីរក្សាជំនឿទុកចិត្តពីសាធារណៈជនចំពោះប្រព័ន្ធតុលាការ គប្បីមានការចូលរួមដោះស្រាយបញ្ហាដែលកើតមានដូចជា៖

-ការប្រើប្រាស់សិទ្ធិបំភ្លឺរបស់តុលាការ គឺជាការពិចារណាទៅលើកម្រិតយល់ដឹងរបស់ភាគីហើយតុលាការក៏ត្រូវគោរពនូវគោលការណ៍អកម្ម ដោយមិនអនុញ្ញាតឱ្យជ្រៀតជ្រែកចូលក្នុងទំនាក់ទំនងរវាងបុគ្គលឯកជនទេ។ តុលាការត្រូវស្វែងរកចំណុចកណ្ដាលមួយ ដើម្បីប្រើប្រាស់សិទ្ធិបំភ្លឺឱ្យស្របតាមស្មារតីច្បាប់ មិនទទួលបានជំនឿទុកចិត្តរបស់ភាគី ជៀសវាងភាគីលើកឡើងថា តុលាការមានភាពលម្អៀង។

-ការអនុវត្តនីតិវិធីរបស់តុលាការឱ្យបានត្រឹមត្រូវ នៅក្នុងការអនុវត្តនីតិវិធី តុលាការត្រូវដឹកនាំចាត់ចែងនីតិវិធីឱ្យមានប្រសិទ្ធភាព ដោយប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍របស់ខ្លួន។ ហើយតុលាការក៏ត្រូវបញ្ចេញអាកប្បកិរិយា និងពាក្យសម្ដីឱ្យបានសមរម្យទៅកាន់គូភាគី ទាំងភាគីដើមចោទ និងភាគីចុងចម្លើយ ពីព្រោះថា នៅក្នុងពេលអនុវត្តនីតិវិធី ប្រសិនបើ តុលាការបង្ហាញអាកប្បកិរិយាមិនសមរម្យទៅកាន់ភាគីណាមួយ ភាគីនោះនឹងយល់ថាតុលាការមានការលម្អៀងទៅកាន់ភាគីម្ខាងទៀត ជាពិសេស ភាគីដែលយល់ថាខ្លួននឹងចាញ់ក្ដី ហើយមានចេតនាទុច្ចរិតអូសបន្លាយពេលវេលា និងយកបញ្ហានេះមកធ្វើជាកម្មវត្ថុប្ដឹងមកតុលាការទោះបីជាតុលាការបានអនុវត្តនីតិវិធីត្រឹមត្រូវហើយក៏ដោយ។

# ឯកសារយោង

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

២. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

៣. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

៤. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៧។

៥. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១ ស្តីពីនីតិវិធីបណ្តឹង ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រសួងយុត្តិធម៌ឆ្នាំ២០០៨។

៦. សៀវភៅស្តីអំពី នីតិវិធីរដ្ឋប្បវេណី រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ី សោភា។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

លេខៈ ..17......(៣) រ.រ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ៦២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ខែ កក្កដា ឆ្នាំ ២០០៦ ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខៈ ២៦៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ។

-រវាងដើមចោទៈ ឈ្មោះ គាំ អាត ភេទប្រុស ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ។

លោក ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ។

-និងចុងចម្លើយៈ ឈ្មោ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១២៩ ផ្លូវលេខ៣១០ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-កម្មវត្ថុនៃបណ្ដឹងៈ ប្ដឹងសុំលែងលះប្ដី។

## សំអាងហេតុ

-ដើម្បីដំណើរការនីតិវិធីបណ្ដឹងទៅតាមច្បាប់ ។

-ដើមចោទពុំទាន់បានបង់ប្រាក់ប្រដាប់ក្ដីដើម្បីធ្វើការកោះហៅភាគី និងសំរាប់បញ្ជូនឯកសារផ្សេងៗ ទៅតាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណីនៅឡើយ ។

## ហេតុដូច្នេះសម្រេច

បង្គាប់ឲ្យឈ្មោះ រ ភេទប្រុស ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ បង់ប្រាក់សម្រាប់បញ្ជូនឯកសារចំនួន ១០០ ០០០រ (ដប់ម៉ឺនរៀល) នៅសាលាដំបូងរាជធានីភ្នំពេញ គិតចាប់ពីថ្ងៃទទួលបានដីកាសម្រេចនេះ រយៈពេល ១៥ថ្ងៃ ជាកំណត់ដើម្បីតុលាការចាត់ការរឿងក្ដីនេះតាមច្បាប់។

បញ្ជាក់ៈ ក្នុងករណីដើមចោទមិនបានបង់ប្រាក់ប្រដាប់ក្ដីទៅតុលាការ តាមការកំណត់នៅក្នុងដីកាសម្រេចនេះ តុលាការនឹងសម្រេចលើកចោលពាក្យបណ្ដឹងទៅតាមច្បាប់។

រាជធានីភ្នំពេញ, ថ្ងៃទី.07. ខែមីនា ឆ្នាំ២០១៧

**ចៅក្រម**

បានទទួល

ថ្ងៃទី..13....ខែ.មីនា ឆ្នាំ២០១៧

ស្នាមមេដៃ

ណា ដាវីណាត (ជំនួយការ)

# ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណី
លេខ :
ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧

## ដីកាកោះ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

អញ្ជើញឈ្មោះ ភេទប្រុស ជាភាគីដើមចោទ។

មានទីលំនៅសព្វថ្ងៃភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ឲ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ "៣"** (ជាន់ទី៤) ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ៨:៣០ នាទី ព្រឹក។

ដើម្បី: **ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។**

ពីដំណើររឿង: **ប្ដឹងសុំទាមទារប្រាក់។**

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.13. ខែកក្កដា ឆ្នាំ២០១៧

**ចៅក្រម**

13/07/17

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណី
លេខ : ២៦៩
ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧

# ដីកាកោះ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

អញ្ជើញឈ្មោះ ជាភាគីចុងចម្លើយ។

មានទីលំនៅសព្វថ្ងៃផ្ទះលេខ១២៩ ផ្លូវលេខ៣១០ សង្កាត់ទូលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ឲ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ "ព"** (ជាន់ទី៤) ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ៨:៣០ នាទី ព្រឹក។

ដើម្បី: ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

ពីដំណើររឿង: ប្តឹងសុំទាមទារប្រាក់។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.១៧. ខែកក្កដា ឆ្នាំ២០១៧

**ចៅក្រម**

ភ្ជាប់មកជាមួយនូវ:
.ពាក្យបណ្តឹងរបស់ឈ្មោះ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ (ថតចម្លង១ច្បាប់)។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

# លិខិតអញ្ជើញ

សំណុំរឿងរដ្ឋប្បវេណី
លេខ :
ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

អញ្ជើញលោក ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ។

មានការិយាល័យស្ថិតនៅផ្ទះលេខ២៧ ផ្លូវលេខ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ឲ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ "ព"** (ជាន់ទី៤) ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ៨:៣០ នាទី ព្រឹក។

ដើម្បី: ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

ពីដំណើររឿង: ប្តឹងសុំទាមទារប្រាក់។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី17 ខែកក្កដា ឆ្នាំ២០១៧

**ចៅក្រម**

[illegible]

17/07/17

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី............ខែ............ឆ្នាំ២០១............ |
| លេខសំណុំរឿង: ............ចុះថ្ងៃទី............ខែ............ឆ្នាំ២០១............ |
| ឈ្មោះឯកសារដែលត្រូវបានបញ្ជូន: ............ |
| ............ |
| ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: លោក ............ |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងរាជធានីភ្នំពេញ |
| ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: ............ |

ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង:............

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កញ្ញាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

| | |
|---|---|
| ទីកន្លែងដែលធ្វើការបញ្ជូន: ............ 129 ............ 310 ............ | |
| កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី...20... ខែ...07... ឆ្នាំ២០១...7... ម៉ោង...11h... ព្រឹក/រសៀល | |
| **វិធីដាក់ស្នូលក្នុងការបញ្ជូន** | |
| ☐១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបានផ្សព្វផ្សាយជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ |
| ☑២ | បានប្រគល់ឯកសារទៅឱ្យអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ ............ |
| ☐៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថា បុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ ☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ ............ |
| ☑ | ខ្ញុំបានបញ្ជូនឯកសារតាមនីតិវិធីខាងលើ |
| ☐ | ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី...20...ខែ...07...ឆ្នាំ២០១...7... | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍: | |

# ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខ: ២៦៩ ចុះថ្ងៃ

ទី៣០ ខែមករា ឆ្នាំ២០១៧

## កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

( តាមបញ្ញត្តិមាត្រា ១១០ និង មាត្រា ១១១ )

សញ្ញាណរឿងក្តី៖ ប្តឹងទាមទារប្រាក់

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែ កក្កដា ថ្ងៃទីម្ភៃប្រាំមួយ វេលាម៉ោងបី និង សាមសិប នាទី ព្រឹក។

ដោយមានសមាសភាព

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

កញ្ញា ក្រឡាបញ្ជីសាលាដំបូងរាជធានភ្នំពេញ

ដើមចោទ ៖ ឈ្មោះ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិប្រការ សង្កាត់ ព្រៃសរ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ។ (អវត្តមាន)

លោក មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ។

ចុងចម្លើយ ៖ ឈ្មោះ លី សុខា ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ១២៩ ផ្លូវ ៣១០ សង្កាត់ ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ (អវត្តមាន)

ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ ៖

-ដើមចោទសុំឲ្យតុលាការសម្រេចចេញសាលក្រម ៖

-ឲ្យចុងម្លើយសងប្រាក់ចំនួន ៦៧៨០ ដុល្លារអាមេរិក

-ការប្រាក់ចំនួន ១៨ ភាគរយក្នុងមួយខែ

-សំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលា សោហ៊ុយក្នុងការប្តឹងផ្តល់ចំនួន ៣០០០ ដុល្លារ

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ

-សុំអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមចំនួន ៦៧៨០ ដុល្លារអាមេរិក

ខ្លឹមសារ និងអង្គហេតុដែលដើមចោទបានអះអាង:

លោក មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទនៅតែរក្សាការទាមទារដូចក្នុងពាក្យបណ្តឹង។ ចំណុចទី១ ខ្ញុំបាទទាមទារឲ្យចុងចម្លើយសងប្រាក់ចំនួន ៦៧៨០ ដុល្លារ ដោយផ្អែកលើកិច្ចសន្យាទិញ លក់ រូបធាតុបេតុងលាយស្រេច ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ចំនួន ៨០២០ ដុល្លារ ហើយនៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ ចុងចម្លើយឈ្មោះ បានសងប្រាក់ចំនួន ១០២០ ដុល្លារ ហើយនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ បានសងចំនួន ៥០០ ដុល្លារ បន្ទាប់មកចុងចម្លើយបានធ្វើកិច្ចសន្យាសងប្រាក់ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៤ ដោយមានឈ្មោះ បានផ្តិតមេដៃតំណាងឲ្យឈ្មោះ លី សុខា សន្យាសងប្រាក់ដែលនៅសល់ចំនួន ៦៧៨០ ដុល្លារ នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៤ ជាកំហិត ប៉ុន្តែចាប់ពីថ្ងៃនោះមកចុងចម្លើយមិនដែលបានសងប្រាក់តាមការសន្យាទេ។ ដូច្នេះ សុំឲ្យសម្រេចតាមការទាមទារខាងលើ។ ចំពោះភស្តុតាងខ្ញុំបាទនឹងដាក់ជូនតុលាការពេលក្រោយ។

ចំណុចវិវាទ ៖

-តើការទាមទាររបស់ដើមចោទមានភស្តុតាងគ្រប់គ្រាន់អាចឲ្យតុលាការជឿជាក់បានដែរ ឬទេ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោងប្រាំបួន និងសូន្យ នាទីព្រឹក នាថ្ងៃខែឆ្នាំដូចខាងលើ។

អានសេចក្តីទាំងស្រុងឲ្យគូភាគីស្តាប់ ថាត្រឹមត្រូវហើយ គូភាគីយល់ព្រមចុះហត្ថលេខា និងផ្តិតមេដៃជាមួយយើង។

**មេធាវីតំណាងដោយអាណត្តិដើមចោទ** **ក្រឡាបញ្ជី** **ចៅក្រម**